ឧប សៅ សង្ហា

# ចលនាគស៊ូខ្មែរ ប្រឆាំងនឹងយួនកុម្មុយនិស្ត

## (១៩៧០-១៩៩១)

ពិនិត្យឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងប្រវត្តិសាស្ត្រខ្មែរ



ឧប សៅ សង្ហា

២៣ កញ្ញា ២០១៨

## មាតិការឿង

សេចក្ដីផ្ដើម 1
ករណី នៃសាធារណរដ្ឋខ្មែរ 16
ករណីខ្មែរក្រហម 43
ករណីចលនាតស៊ូខ្មែរ នៅតាមព្រំដែន ខ្មែរ-ថៃ 62
សេចក្ដីសន្និដ្ឋាន 76
ឧបសម្ព័ន្ធ 87



## សេចក្ដីផ្ដើម

នៅសតវត្សទី២០, គេអាចនិយាយបានថា ការតស៊ូ របស់ខ្មែរ គឺ ប្រឆាំងនឹងយួនកុម្មុយនិស្ដ។ តែការតស៊ូនោះ តែងតែមានខ្មែរមួយក្រុម ជួយយួន ដែលនាំអោយមាន ស្នាមប្រេះ នៃសង្គមជាតិខ្មែរ ហើយ កាលណា មានការតស៊ូប្រឆាំងនឹងយួនម្ដងណា បណ្ដាលអោយមានកើតសង្គ្រាមស៊ីវិល។ ដូច្នេះ កត្តាយួន វាក្លាយជា កាកំណត់ នៃជម្លោះខ្មែរនិងខ្មែរ នៅពេលណា ដែលខ្មែរ មានទំនាស់នឹងយួន។ ការណ៍នេះ ដែលនាំខ្មែរ ជជែកគ្នា រកហេតុផលមិនចេះចប់រហូតមកដល់សព្វថ្ងៃ ហើយ គ្មានគំនិតណាមួយ ជាការពន្យល់សមហេតុសមផល អំពីបញ្ហានេះ តែ ផ្ទុយទៅវិញមានតែសំដីផ្ដេសផ្ដាស់ ដែលវាក្លាយជា វប្បធម៌ខ្មែរ នៅក្នុងការពិភាក្សាសានយោបាយ សំរាប់តែជម្រះគ្នា តាមទស្សនះរៀងៗខ្លួន តែប៉ុណ្ណោះ ដូចជា គំនិតជាតិ ទាំងឡាយនោះ វាមាន នៅក្នុងផ្សារ លក់តម្លៃ ដ៏ថោកបំផុត ដែលនរណា ក៏អាច មកជ្រើសរើសទិញ យកទៅប្រើ ដើម្បីបង្ហាញ នូវទស្សនៈផ្ទាល់ខ្លួន តាម ហ្វេសប៊ុក ឬ បណ្ដាញ internet។ ការណ៍នេះ ក៏បង្ហាញអោយឃើញដែរថា ការប្រេះ

ឆា នៅក្នុងសង្គមខ្មែរ វាធំ និង ជ្រៅ ខ្លាំងណាស់ទៅហើយ។ គេអាចម៉ែថា សង្គមខ្មែរសព្វថ្ងៃ លែងមាន ឯកភាពជាតិ សំរាប់ដោះស្រាយបញ្ហាជាតិដោយខ្លួនឯង។ ជាការពិត, បញ្ហាឯកភាពជាតិ គឺ ការប្រទល់គ្នា នៃរបបដឹកនាំពីរយ៉ាង : របបប្រជាធិបតេយ្យសេរី និង របបផ្តាច់ការ ហើយនៅក្នុងបញ្ហានេះ វាមានកត្តាយួន ជាវត្ថុធាតុរំខានមួយនៅក្នុងជម្រើស របស់ប្រជាពលរដ្ឋខ្មែរ តាំងពីទស្សវត្សរ៍ ១៩៥០ មកម្លេះ។ ហើយ មកដល់សព្វថ្ងៃ មាន ជនជាតិយួនរាប់លាននាក់ មករស់នៅស្រុកខ្មែរ មានសញ្ជាតិ ជា ជនកម្ពុជា មានសិទ្ធិគ្រប់បែបយ៉ាងជា ពលរដ្ឋខ្មែរ។ ដូច្នេះ ការផ្លាស់ប្តូរ នៃសង្គមខ្មែរ ចាប់ពីឆ្នាំ ១៩៧៩ វាមានល្បឿនលឿនណាស់ គឺអាចប្តូរពី រូបភាព នៃ សង្គមសភាគ ទៅជាសង្គមពហុជាតិសាសន៏ ហើយវាស្ទើរតែលុបបាត់ នូវចរិតលក្ខណៈ របស់ជាតិសាសន៏ខ្មែរ ដែលជាម្ចាស់ស្រុក។

ការរកសទ្ធាន[1]ជាតិ នៅជុំវិញ ប្រយោជន៍ជាតិ វាពិបាក នឹងមាន ព្រោះ សង្គមពហុជាតិសាសន៍សព្វថ្ងៃ គឺជាការ បង្ករសិប្បនិម្មិត បង្កើតឡើង ដើម្បីបំរើប្រយោជន៍យួន សុទ្ធសាធ ដែលនៅក្នុងសង្គមនោះ យួន គេធ្វើគ្រប់បែប យ៉ាង ដើម្បី លុបបំបាត់ នូវសញ្ញាណ នៃប្រជាជាតិខ្មែរ ដោយយក សញ្ញាណ នៃ រដ្ឋ-ជាតិសាសន៍ មកជំនួសវិញ។ តែ ទង្វើនេះ វាគ្រាន់តែជាការបន្ត នៃដំណើរ នៃជាតិសាស ន៍យួន ពីទិសខាងលិច មកទិសខាងកើត តាមល្បឿន លឿនជាទីបំផុត ដើម្បី អោយស្របនឹង សុភកាលរបស់ ស្រុកខ្មែរ គឺ អវត្តមាន នៃគំនិតជាតិនិយម និង បញ្ញា ជាតិ ដើម្បី ការពារប្រជាជាតិ។ ចំពោះយួន ស្រុកខ្មែរសព្វ ថ្ងៃ គឺដូចជា តុក្កតា អាចកំរើកដៃជើងបានដោយខ្សែ ដែលយួន ជាអ្នកទាញ អោយកំរើក ទៅតាមការចង់បាន របស់គេ។ តើ មានខ្មែរណាម្នាក់នៅសតវត្សទី២០ នឹកស្មាន បានថាមាន ថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ ?

---

[1] ការព្រមព្រៀងគ្នា ; consensus។

ចំពោះគណបក្សកុម្មុយនិស្តយួន គេទុក ថ្ងៃទី៧ មករា មិនមែនជា ថៃ្ងដន្យ, វាជា កម្មវិធីនយោបាយពិស្តារ ហើយមានជំនឿជាក់ច្បាស់ថា នឹងអាចធ្វើ អោយបានសម្រេច។ ចំពោះសម្តេច សីហនុ[2] នៅទស្សវត្ស ៤០-៥០ ដឹងច្បាស់អំពីគ្រោះថ្នាក់នេះ ដូចអ្នកស្នេហាជាតិខ្មែរដទៃទៀត នាំគ្នាតស៊ូប្រឆាំងនឹងយួនយៀកម៉ិញ។ ពួកនោះ បានចូលមកធ្វើសកម្មភាពនយោបាយ និង សឹក នៅស្រុកខ្មែរ ប្រឆាំងនឹងបារាំង។ នៅពេលជាមួយគ្នានោះ មានចលនាតស៊ូខ្មែរមានឈ្មោះថា ចលនាតស៊ូខ្មែរតស្សរៈ, ជាចលនាប្រឆាំងនឹងអាណានិគមបារាំង ដើម្បីឯករាជ្យជាតិ។ ចលនានេះមានទីតាំងនៅតាមបណ្តោយព្រំដែន ខ្មែរ-សៀម ហើយមានការគាំទ្រពីសៀម។ ចលនានោះ បែកជាក្រុមតូចជាច្រើន ហើយមានអ្នកដឹកនាំល្បីៗ គឺ លោកស្រី លាត មួន,

---

[2] សម្តេច សីហនុ ជាអ្នកដឹកនាំខ្មែរ តែមួយអង្គឯងគត់ អស់រយៈពេល ២៨ឆ្នាំ គឺ ពីឆ្នាំ ១៩៤១ ដល់ ១៩៦៩។

លោក ប៉ុក យុន[3], សឹង ង៉ុកថាញ់, ដាប ឈួន, នរោត្ដម ចន្ទរង្សី, សារ៉ាំង វង្ស, កៅ តក់, អ៊ុំច, គ្រូអ៊ុំម, ពុត ឆាយ, ប៉ុនចន្ទ មុល...។ ក្រោយបន្ដិចមក ពួកយួនកុម្មុយនិស្ដ ឬ យៀកម៉ិញ គេបង្កើតចលនាតស៊ូខ្មែរ ប្រឆាំងនឹងអាណានិគមបារាំងមួយដែរ ដឹកនាំដោយលោក សឹង ង៉ុកមិញ ដែលជាជនយួន តែប្រឡំខ្លួនធ្វើជាខ្មែរកម្ពុជាក្រោម និង ជនខ្មែរមួយចំនួន គឺ អាចារ្យ សារឿន, សុខ សាផៃ, លោក ហុង ឈុន, លាវ កែវមុនី, អៀ ស៊ីចូវ, ស៊ីវ ហេង...។ នៅខែ មករា ឆ្នាំ ១៩៤៩, ចលនាតស៊ូខ្មែរឥស្សរៈ បានដូរឈ្មោះថា ចលនារំដោះជាតិខ្មែរ (KNLC) ដែលមាន ដាប ឈួន ជា ប្រធាន និង កៅ តក់ ជាអនុប្រធាន។ ក្រោយបន្ដិចមក លោក កៅ តក់ ក្បត់លោក ដាប ឈួន លួចចូលធ្វើសហការណ៍ជាមួយ យៀកម៉ិញ។ នៅខែ កុម្ភៈ ឆ្នាំ ១៩៥១ លោក លាវ កែវមុនី ត្រូវបានគេជ្រើសរើសធ្វើជាប្រធានជំនួស

---

[3] លោកស្រី លាត មួន និង លោក ប៉ុក យុន ជាជនខ្មែររស់នៅស្រុកសៀម បានជួយជាជំនួយសម្ភារៈ និង ទាក់ទងនឹងអាជ្ញាធរសៀម ដើម្បីបង្កើតចលនាតស៊ូខ្មែរឥស្សរៈ។

លោក ដាប ឈួន, តែនៅពេលប្រជុំតែងតាំងនោះ គ្មានវត្តមានលោក កៅ តក់ ដែលនាំអោយគាត់ មានកំហឹងខ្លាំងណាស់ បណ្តាលអោយមាន ការប៉ុនបងលួចធ្វើឃាតលោក លាវ កែវមុនី តែមិនបានស្រេចដូចបំណង។ នៅថ្ងៃទី ១៣ កក្កដា ឆ្នាំ ១៩៥១ ចលនារំដោះជាតិខ្មែរ បានប្រារព្ធធ្វើបុណ្យរួបរួមសាមគ្គីគ្នាឡើងវិញ រវាង ក្រុមផ្សេងៗ ក្រោមអធិបតីរបស់លោក សឺង ង៉ុកថាញ់។ នៅពេលនោះគេឃើញមានវត្តមានលោក កៅ តក់, អៀ ស៊ីចូវ, លាវ កែវមុនី, ទុំសុខ, អ៊ុំម និង ធឹម ត្រឡៃ ព្រមទាំងទាហ៊ានគ្រប់ក្រុមទាំងអស់ចូលរួម។ ក្រោយបន្តិចមកលោក សឺង ង៉ុកថាញ់ បានផ្ញើលិខិតអញ្ជើញលោក ពុត ឆាយ, ទ្រង់ ចន្ទរង្សី និងលោក ស៊ីវ ហេង ទៅចូលរួមប្រជុំ នៅស្វាយស៊ីសុផុន នៅថ្ងៃទី ២៧ វិច្ឆិកា ឆ្នាំ ១៩៥២ ដើម្បីជ្រើសរើស មេដឹកនាំខ្មែរឥស្សរៈជាន់ខ្ពស់ម្នាក់ សំរាប់ដឹកនាំចលនាតែមួយ។ នៅពេលនោះ មានតែលោក កៅ តក់, ពុត ឆាយ និង ទ្រង់ចន្ទរង្សី ទេ បានចូលរួមប្រជុំ ហើយទទួលស្គាល់ ការជ្រើសរើសលោក សឺង ង៉ុកថាញ់ ជាមេដឹកនាំជាន់ខ្ពស់ ព្រោះលោក លាវ កែវ មុនី មិនបានចូលរួមប្រជុំ ព្រោះគាត់មាន

បញ្ហាផ្ទៃក្នុង របស់ក្រុមគាត់។ ត្រូវដឹងថា លោក សឺង ង៉ុកថាញ់ គាត់មាននិន្នាការទៅរកពួកយៀកម៉ិញ ព្រោះគាត់យល់ឃើញថាគ្រោះថ្នាក់ខ្មែរ ចេញពីសៀម ច្រើនជាងយួន។ នៅឆ្នាំ ១៩៥២, ពួកយួនយៀកម៉ិញ និង ខ្មែរយៀកម៉ិញ ត្រួតត្រាដែនដីខ្មែររំដោះនៅស្រុកខ្មែរ ច្រើនជាងចលនាតស៊ូខ្មែររំដោះ[4]។ អាស្រ័យហេតុនេះ បានជាគណៈប្រតិភូយួនកុម្មុយនិស្ត នៅពេលសន្និសិទ្ធ នៅទីក្រុងសឺណែវ ឆ្នាំ ១៩៥៤ ស្នើដល់អង្គប្រជុំ អោយផ្តល់ទឹកដីមួយផ្នែកអោយពួកខ្មែរយៀកម៉ិញត្រួតត្រា ដែលយួនគេដាក់ឈ្មោះថា រណសេរ្យតស៊ូសម្ព័ន្ធឥស្សរៈ[5] (UIF) តែសំណើរនេះត្រូវបានបដិសេធដោយតំណាងសហរដ្ឋអាមេរិក, បារាំង

[4] បួនភាគប្រាំ នៃដែនដីខេត្តកំពង់ធំ និង កំពត គឺជាដំបន់ត្រួតត្រាដោយពួកយៀមមិញ។

[5] ពួកនេះប្រើទង់ជាតិរូបអង្គរកំពូលប្រាំ ហើយពួកនេះឯងដែលយួនយកមកប្រើជាឈ្មោះ សំរាប់វាយចូលស្រុកខ្មែរនៅឆ្នាំ ១៩៧៨-១៩៧៩ ហើយទទួលបានជ័យជំនិះនៅថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ លើកម្ពុជាប្រជាធិបតេយ្យ។

និង អង់គ្លេស។ ផ្ទុយទៅវិញ សន្ធិសិទ្ធនោះ បានបញ្ចូលដែនដីខ្មែរកម្ពុជាក្រោម ទៅក្នុងទឹកដីយួនខាងត្បូង[6]។ យើងឃើញថា ទោះបីលោក សឹង ង៉ុកថាញ់ ជាមេដឹកនាំតែមួយ នៃចលនារំដោះជាតិខ្មែរ តែចលនានោះ គ្មានឯកភាពនយោបាយ និង យោធា នោះទេ បណ្តាលអោយមានជម្លោះអារុំផរឿយៗ រវាង ក្រុមនិមួយៗ ជាពិសេស រវាងក្រុមអ្នកជាតិនិយម និង ក្រុមខ្មែរវៀតមិញ។ កងទ័ពព្រៃរំដោះនោះ បានបែងចែកស្រុកខ្មែរ ជាបួនតំបន់ គឺ តំបន់អគ្នេយ៍ ត្រួតត្រាដោយលោក លាវ កែវ មុនី, តំបន់ ឥសានដឹកនាំដោយលោក សឺន ស៊ីថាន់, តំបន់និរតី ដឹកនាំដោយលោក សឺន ង៉ុកថាញ់ និង តំបន់ពាយព្យ ដឹកនាំដោយលោក ដាប ឈួន។ លោក ដាប ឈួន គាត់មានទំនាក់ទំនងជាមួយសៀមផង និងជាមួយវៀតមិញផង ហើយគាត់មានទាហ៊ានចំនួន ៤០០នាក់។

[6] នៅពេលសន្ធិសិទ្ធនោះ គេបែកចែកស្រុកយួនជាពីដំបន់បណ្តោះអាសន្ន គឺ យួនខាងត្បូង ឬ យួនសេរី និង យួនខាងជើង ឬ យួនកុម្មុយនិស្ត ដែលមានខ្សែស្របទី១៧ ជាព្រំដែននយោបាយ និង យោធា។

នៅឆ្នាំ ១៩៥៤ លោក សឹង ង៉ុកថាញ់ ត្រូវសម្ដេច សីហនុ ទុកលោកជាសត្រូវនយោបាយ ហើយ ទ្រង់ ថែមទាំង បដិសេធ នូវការសុំចុះចូល និង សេចក្ដីសន្យាស្មោះត្រង់ នឹងរាជរដ្ឋាភិបាលខ្មែរ ដែលនាំអោយលោក សម្រេចចិត្ត ទៅរស់នៅតាមព្រំដែន ខ្មែរ-ថៃ ហើយ បន្តតស៊ូអាវុធ ប្រឆាំងនឹងនយោបាយ របស់សម្ដេចសីហនុ ដែលលោក ទុកជាគ្រោះថ្នាក់មួយដល់ប្រជាជាតិខ្មែរ។ បន្ទាប់ពីសន្និ សិទ្ធ នៅទីក្រុងសឺណែវ, ពួកយៀកមិញ ត្រូវដកទ័ពខ្លួន ចេញពីស្រុកខ្មែរ ដោយនាំជនខ្មែរស្មោះត្រង់នឹងខ្លួនចំនួន ៤ពាន់នាក់ទៅតាមខ្លួន ចំណែក មេដឹកនាំ នៃក្រុមនិមួ យៗ នៃចលនាតស៊ូរំដោះជាតិខ្មែរ បានសុខចិត្តចុះចូល រាជរដ្ឋាភិបាលខ្មែរ នៅក្នុងក្របខណ្ឌ នៃនយោបាយ បង្រួបបង្រួមជាតិ ដែលមានសម្ដេចសីហនុ ជាអ្នកដឹងនាំ ក្នុងនាមជាបីតា នៃឯករាជ្យជាតិ។ ការណ៍ទាំងឡាយនេះ វា ហាក់បីដូចជា បញ្ហាខ្មែរនិងខ្មែរ និង ខ្មែរនិងយួន វាបញ្ចប់ ដោយសន្តិផ្ទិភាពល្អប្រសើរ ដែលវាអាចហុចឱកាស អោយ ខ្មែររួមគ្នាជាកម្លាំងជាតិ កសាងស្រុកខ្មែរឯករាជ្យ អោយ បានចំរើនលូតលាស់គ្រប់វិស័យជាតិ និង មនុស្សជាតិ។ តែ

នៅស្រុកយួន សង្គ្រាមនៅមានបន្តជានិច្ច រវាង យួនខាងត្បូង និង យួនខាងជើង នៅក្នុងបរិបទសង្គ្រាមត្រជាក់ រវាងលោកសេរី និង លោកកុម្មុយនិស្ត។ សង្គ្រាមនេះ តម្រូវអោយសម្តេចសីហនុ ជ្រើសរើសយក គោលជំហរអព្យាក្រឹត នៅចំពោះមុខមហាអំណាច នៃលោកសេរី និង លោកកុម្មុយនិស្ត និង យួនខាងត្បូង និង យួនខាងជើង ព្រោះជាផ្លូវតែមួយគត់ សំរាប់រក្សាស្រុកខ្មែរ ឲរស់ក្នុងសន្តិភាព នៅក្នុងសង្គ្រាមយៀកណាម រវាង យួនខាងជើង មានជំនួយពី លោកកុម្មុយនិស្ត និង យួនខាងត្បូង មានវត្តមាន យោធាអាមេរិកកាំង នៅយួនខាងត្បូង ជា បង្អែក។ ការជ្រើសរើសអង្គការ នៃប្រទេស មិនចូល ក្នុងប្រតិព័ន្ធ (bloc) ណាមួយ ជា ការបញ្ជាក់បន្ថែមទៀត នូវការប្តេជ្ញាចិត្តរបស់សម្តេចសីហនុ យកអព្យាក្រឹតភាព ជា ខែល សំរាប់ការពារឯករាជ្យជាតិ, បូរណភាពដែនដីជាតិ និង សន្តិភាព នៃប្រជាជាតិខ្មែរ។ តែក្នុងកំឡុងពេលកាន់ អំណាច ជា ប្រមុខរដ្ឋផ្តាច់ការ ដែល ឥតមាន កំណត់ព្រំដែនអាណត្តិ និងអំណាចនោះ, សម្តេចសីហនុ បាន ចាត់ចែងកិច្ចការ និង នយោបាយ របស់ប្រទេសតាម តែ អំពើចិត្ត។

ទ្រង់ ចាត់ទុក យួនខាងជើង និង យៀកកុង ជា « បងប្អូន » និង ជា « មិត្ត » របស់ព្រះអង្គ។ ជាពិសេស ចាប់តាំង ពី ឆ្នាំ ១៩៦៥ ទ្រង់ បាន ក្បត់នឹង នយោបាយ អព្យាក្រឹត នាំទ្រង់ អោយ អនុញ្ញាតឲ ទ័ពយួនខាងជើង និង យៀកកុង ចូលមកតាំង មូលដ្ឋានសឹកពាសពេញ នៅក្នុង ទឹកដីខ្មែរ ជា ពិសេស ក្នុងខេត្តខ្មែរទាំងឡាយ នៅ ប៉ែក ខាងកើត តាំង ពី រតនគិរី រហូតមកដល់ មាត់សមុទ្រ ដើម្បី ឲពួកនេះ ចេញទៅ វាយប្រហារ យៀកណាមខាងត្បូង។ ក្រៅពីនេះ ទ្រង់ បានអនុញ្ញាត ដោយ សម្ងាត់ ឲយួន ខាងជើង និង យៀកកុង ប្រើប្រាស់ កំពង់ផែ កំពង់សោម ដើម្បី ដឹកនាំ គ្រឿងអាវុធ និងគ្រាប់រំសេវ យក ទៅផ្តល់ ឲ កងទ័ព របស់ខ្លួន ធ្វើ សង្គ្រាមឈ្លានពាន នៅ យៀកណាម ខាងត្បូង។ ដោយ បាន សេចក្តីអនុញ្ញាត ពី ទ្រង់ តាមរយៈ នៃ កិច្ចព្រមព្រៀងសម្ងាត់ ពួកទ័ពយួនខាងជើង និង យៀកកុង ដែល ចូលមក តាំងទី នៅលើ ទឹកដីខ្មែរ បាន ប្រកាន់ ឫកពា ជា ម្ចាស់ លើទឹកដីនេះតែម្តង។ ពួកគេ បាន លួចប្លន់ យក ភោគផល របស់រាស្ត្រខ្មែរ តាម អំពើចិត្ត ដើម្បី យក ទៅ ចិញ្ចឹមទ័ពខ្លួនកំពុង ធ្វើ សង្គ្រាមនៅ

យៀកណាមខាងត្បូង។ មិនតែប៉ុណ្ណោះ ពួកឈ្លានពាន ទាំងនេះ បាន ធ្វើ បាបជិះជាន់ រាស្ត្រខ្មែរស្លូតត្រង់ ដែល មិនពេញចិត្តនឹងខ្លួន ដោយឥត មាន ការរអែងអ្វី សោះ ឡើយ។ នៅចំពោះមុខ សភាពការណ៍ បែបនេះ ប្រជារាស្ត្រ ខ្មែរ ជាពិសេស ប្រជាពលរដ្ឋ នៅ តំបន់ ទាំងឡាយ ដែល ទ័ពយួនខាងជើងនិង យៀកកុង ចូល កាន់កាប់ កើត ក្តី ក្តៅក្រហាយ យ៉ាងខ្លាំង។ បាតុកម្ម ជា ច្រើនក៏បានផ្ទុះ ឡើង ប្រឆាំងនឹង វត្តមាន របស់ ទ័ពយួនខាងជើង និង យៀកកុង នៅលើទឹកដីខ្មែរ។ ជា ដំបូង បាតុកម្ម ផ្ទុះឡើង នៅ ខេត្តស្វាយរៀង នៅ ថ្ងៃ ទី៨ មីនា១៩៧០។ នៅ ថ្ងៃ បន្ទាប់មក បាតុកម្ម របៀបនេះ ក៏ បាន រាលដាល មក ដល់ ក្រុងភ្នំពេញ។ ជា ពិសេស នៅ ថ្ងៃ១១ មីនា ១៩៧០ បាតុកម្ម ដ៏គគ្រឹកគគ្រេង បាន ផ្ទុះឡើង ប្រៀបបាននឹង ទឹក ហូរ បាក់ទំនប់ ពុំមានអ្វី អាចទប់បាន ប្រឆាំងនឹង ស្ថានទូត យួនខាងជើង និង យៀកកុង នៅ កណ្តាល ក្រុង ភ្នំពេញ តែម្តង។ ក្នុងបំណង សម្រុះសម្រួល នៅ ថ្ងៃ១២ មីនា រដ្ឋាភិបាលស្រោចស្រង់ជាតិ បានស្នើសុំឲ្យយួនខាងជើង និងយៀកកុង ដកកងកម្លាំងរបស់ខ្លួន ថយចេញពីទឹក

ដីខ្មែរឲអស់នៅត្រឹមថ្ងៃ១៥មីនា១៩៧០។ តែ យួនខាងជើង និង យៀកកុង ឥតបានយកចិត្តទុកដាក់ ដល់សំណើរនេះទេ។ នៅ ព្រឹក ថ្ងៃ១៦ មីនា បាតុកម្ម ដ៏ធំមួយ ក៏បានផ្ទុះឡើង ជា ថ្មី ទៀត នៅ ក្រុងភ្នំពេញ ទាមទារ ឲទ័ពយួនខាងជើង យៀកកុង ឆាប់ថយចេញ ពីទឹកដីខ្មែរ។ ដោយ ចង់ដោះស្រាយ បញ្ហានេះ ឲបានឆាប់រហ័ស និង ដោយ សន្តិវិធី រដ្ឋាភិបាលខ្មែរ ក៏ បាន ស្នើ បើក ការចរចាមួយលើកទៀត នៅ ថ្ងៃ១៦ មីនា ជា មួយនឹង ពួកតំណាងយួនខាងជើង និង យៀកកុង នៅភ្នំពេញ។ ប៉ុន្តែ ដូច គេបានដឹងស្រាប់ហើយថា, ជំនួបនោះ ពុំ មានលទ្ធផលអ្វីបន្តិចបន្តួចសោះទេ ព្រោះ ពួកយួនកុម្មុយនិស្ត នៅ តែ ប្រកាន់ អាកប្បកិរិយា រឹងត្អឹង និង លាក់ពុតដដែល ជាពិសេស ពួក គេបានគេចវេះមិនព្រមនិយាយអំពី បញ្ហាដកកងទ័ព របស់គេ ចេញ ពី ទឹកដីខ្មែរ ដែល ជា កម្មវត្ថុ តែមួយគត់ នៃការចរចានោះទៀតផង។ ពួកគេ បាន ឆ្លើយ ទាំងព្រហើនថា ទ័ពគេ ដែល ចូលមកតាំង លើទឹកដីខ្មែរគឺ បាន ទទួល សេចក្ដីអនុញ្ញាត ពី ស្ដេចសីហនុ។ នៅមុខ សភាពការណ៍ ដ៏ធ្ងន់ធ្ងរ បែបនេះ ក្រុម អ្នកដឹកនាំខ្មែរ ពេលនោះ ក៏ បាន

ផ្ញើ សេចក្តីរាយការណ៍ ផ្ញើ ទៅ ស្តេចសីហនុ ដែល កំពុងព្យាបាលរោគ នៅ ប្រទេសបារាំង ដើម្បីថ្វាយ នូវដំណឹងពិតអំពីហេតុការណ៍ ដែលកំពុងមានកើតឡើង នៅក្នុងស្រុក។ តែ គួរឲស្តាយ ក្នុង សាទូរលេខមួយច្បាប់ ផ្ញើ មក ពី ក្រុងបារីស៍ តបមកអ្នកដឹកនាំ នៅក្នុងប្រទេសវិញ, សម្តេចសីហនុ មិនត្រឹម តែ ចេញមុខ កាន់ជើង យួនខាងជើង និង យៀកកុង ថែម ទាំង បាន ចោទបាតុករខ្មែរថាជាពួក « ក្បត់ជាតិ » ផ្ញើ តាម ខ្សែ ញាក់ញាះញង់ របស់ចក្រពត្តិអាមេរិកាំង។ សម្តេចសីហនុ បាន ភ្លេចថា ខ្លួនជា ខ្មែរ ហើយ ភ្លេចនឹកគិត ដល់ ប្រយោជន៍ជាតិ ជាធំ បែរទៅជាកាន់ជើងពួកសត្រូវនឹងប្រជារាស្ត្រខ្មែរទៅវិញ។ នៅចំពោះមុខ ឥរិយាបថមិនទំនង របស់សម្តេចសីហនុ សភាទាំងពីរ គឺ រដ្ឋសភា និង ក្រុមព្រឹក្សារាជាណាចក្រ រួមប្រជុំនៅ ថ្ងៃ១៨ មីនា ១៩៧០ បោះឆ្នោតទម្លាក់សម្តេចសីហនុចេញពីតំណែង ប្រមុខរដ្ឋ ស្របតាម មាត្រា ១២២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧។

ដោយ ក្តៅក្រហាយនឹង ប្រជារាស្ត្រខ្មែរ តាម រយៈ នៃ សភាទាំងពីរ ដែលបានទម្លាក់ ខ្លួន ចេញពី មុខតំណែង សម្តេច

សីហនុ ក៏ បាន ផ្សាយសារមួយច្បាប់ ពី ក្រុង ប៉េកាំង នៅ ថ្ងៃ២៣ មីនា ឆ្នាំ ១៩៧០ អំពាវនាវ ហៅ កងទ័ពយួនខាងជើង យៀកកុង ដែលមានទីតាំង ពាសពេញ លើ ទឹកដីខ្មែរ ស្របតាម ការសមគំនិត របស់ព្រះអង្គ ឲបើក ការវាយប្រហារ ស្រុកខ្មែរ ដើម្បី ជួយព្រះអង្គ ឲវិលត្រឡប់ មកកាន់អំណាចវិញ។ តាម សេចក្តីអំពាវនាវនេះ ទ័ពយួនខាងជើង និង យៀកកុង ក៏បានចាប់ផ្តើម បើកការវាយប្រហារ យ៉ាងចេញមុខ និង យ៉ាងសាហាវព្រៃផ្សៃ មកលើកងទ័ពជាតិខ្មែរ ចាប់ពី ថ្ងៃ២៩ មីនា ១៩៧០ ដោយគ្មានធ្វើការប្រកាសសង្គ្រាមជាមុន។ សង្គ្រាមនៅស្រុកខ្មែរ កើតមានឡើងដូច្នេះឯង ដែលបណ្តាលអោយប្រជាពលរដ្ឋ ជួបប្រទះនូវទុក្ខសោកគ្រប់បែបយ៉ាង។



ទ្រង់សិរិមត, លោក លន់ នល់, លោក អ៊ិន តាំ

## ករណី នៃសាធារណរដ្ឋខ្មែរ

នៅចំពោះមុខការវាយប្រហារខ្លាំងក្លា របស់កងទ័ពយៀកកុង[7] មកលើកងទ័ពខេមរភូមិន្ទខ្មែរ តម្រូវអោយ រាជរដ្ឋភិបាលស្រោចស្រង់ជាតិ[8] ចាត់វិធានការ ការពារជាតិជាប្រញាប់។ ការប្រកាស របបសាធារណរដ្ឋ ជាផ្នែកមួយសំខាន់ នៅក្នុងយុទ្ធសាស្ត្រ នយោបាយ-យោធា សារុប ដើម្បីដោះស្រាយ បញ្ហាដ៏ធំមួយ ដែលប្រជាជាតិខ្មែរកំពុងជួបប្រទះ ព្រោះ ស្តេចសីហនុ នៅក្រោមឥទ្ធិពលចិន និងយួនកុម្មុយនិស្ត ទ្រង់សុខចិត្ត ថ្វាយព្រះនាមទ្រង់ អោយគេយកទៅប្រើ តាំងជាប្រធាន រណសេរ្សជាតិបង្រួបបង្រួមជាតិខ្មែរ និង រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិខ្មែរនៅ

[7] កងទ័ពយួនខាងជើង និង យៀកកុង មានចំនួន ៦ ម៉ឺន នាក់ នៅក្នុងស្រុកខ្មែរនៅពេលនោះ ហើយ ប្រដាប់ដោយអាវុធយ៉ាងទំនើប។ ចំពោះលោក Nixon ប្រធានាធិបតីអាមេរិកាំង បាន់ស្មានថាមាន ទ័ពកុម្មុយនិស្ត នៅក្នុងស្រុកខ្មែរចំនួន ១០ ម៉ឺននាក់។ នៅឆ្នាំ ១៩៦៨, សម្តេចសីហនុ បានបាន់ស្មានថាមាន ៨ ម៉ឺននាក់។ត្រូវដឹកថា កងទ័ពខេមរភូមិន្ទ មានចំនួនតែ ៣ ម៉ឺននាក់តែប៉ុណ្ណោះ ឯសម្ភារៈសឹកវិញ ក៏ហួសសម័យដែរ។

[8] រាជរដ្ឋាភិបាលនេះ គឺសម្តេចសីហុន ជាអ្នកបង្កើត នៅឆ្នាំ ១៩៦៩ ហើយទ្រង់ជ្រើសរើសលោក លន់ នល់ ជាអ្នកដឹកនាំ។

ក្រៅស្រុក នៅក្នុងនោះមាន ពួកខ្មែរក្រហម និង ខ្មែរយៀកមីញ រួមគ្នា នៅក្រោមបញ្ជាការយួនផ្ទាល់។ ដោយយល់ឃើញថា ស្តេចសីហនុ ជានិមិត្តរូប នៃរបបរាជានិយម តែបែរជាព្រះអង្គ ទៅបំរើប្រយោជន៍សត្រូវជាតិ ជាបរទេស ដោយយកឈ្មោះខ្មែរជាឡប់ឡែ ដូច្នេះតម្រូវអោយប្រជាពលរដ្ឋខ្មែរ ប្តូររបបដឹកនាំចាស់ ដែលជា របបធ្វើអោយខូចកិត្តិយសជាតិ ជ្រើសយករបបថ្មី គឺ របបសាធារណរដ្ឋ[9] ដែលជារបប តំណាង នូវប្រជាអំណាច, សេរីភាព និង កម្លាំងជាតិពិត ដែលប្រជាជាតិខ្មែរ ត្រូវការជាចាំបាច់ ដើម្បី តស៊ូប្រឆាំងនឹងយួនកុម្មុយនិស្ត ជាអ្នកឈ្លានពាន នៃអធិបតេយ្យភាព និង បូរណភាពទឹកដី នៃប្រជាជាតិខ្មែរ ដោយបំពានច្បាប់ អន្តរជាតិទាំងស្រុង។ ដូច្នេះ សង្គ្រាម កើតឡើងនៅឆ្នាំ ១៩៧០ ជាសង្គ្រាមបង្កើតឡើងដោយយួនកុម្មុយនិស្ត ដែលមានស្តេចសីហនុ និង ខ្មែរក្រហម ជួយគាំទ្រ ក្នុងឋានៈជាអ្នកបំរើប្រយោជន៍យួនសុទ្ធ

[9] បាវចនា នៃសាធារណរដ្ឋខ្មែរ គឺ សេរីភាព សមភាព ភាតរភាព វឌ្ឍភាព និង សុភមង្គល។

សាធ។ សួរថា តើប្រជាពលរដ្ឋខ្មែរ ត្រូវធ្វើដូចម្តេច នៅចំពោះមុខសភាពការណ៍បែបនេះ ? ចម្លើយប្រក្សត្រ គឺការតស៊ូការពារជាតិ។ ហើយ សាធារណរដ្ឋខ្មែរ ជាតំណាងនៃការតស៊ូជាតិនោះឯង។ ស្រុកខ្មែរ ជាប្រទេសមួយតូច ហើយ ក្រ ដូច្នេះ គ្មានមធ្យោបាយគ្រប់គ្រាន់ ក្រៅពីទឹកចិត្ត នៃយុវជន និង ប្រជាពលរដ្ឋ ដើម្បីការពារខ្លួន នៅចំពោះមុខការរំជំរំជែង នៃកងទ័ពយួនកុម្មុយនិស្ត។ ដូច្នេះ ស្រុកខ្មែរ ត្រូវការជំនួយពី នគរជាមិត្ត ជាពិសេសពី សហរដ្ឋអាមេរិក ដែលជាតំណាងកំពូល នៃអ្នកប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត ហើយជា នាដការផ្ទាល់ នៅក្នុងសង្គ្រាមការពារសេរីភាព និង លទ្ធិប្រជាធិបតេយ្យនៅយៀកណាម។ ការពឹងផ្អែងនេះ ជាកិច្ចធម្មានុរូប[10] នៃប្រជាពលរដ្ឋខ្មែរ ដែលជាអ្នករងគ្រោះ នៃអំពើបំពានច្បាប់អន្តរជាតិ ពីសំណាក់កងទ័ពយួនកុម្មុយនិស្ត មកលើស្រុកខ្មែរ។ តែនៅក្នុងបរិបទ នៃនយោបាយអាមេរិកាំង ដកខ្លួនចេញពីយៀកណា

[10] Acte légitime.

ម, សហរដ្ឋអាមេរិក បានប្រគល់ជំនួយអោយខ្មែរ ក្នុងកំរិតទាប ហើយជាជំនួយស្ថិតនៅក្នុង យុទ្ធសាស្ត្រ នៃសង្គ្រាមនៅយៀកណាម។ ជាឧទាហរណ៏ សភាពការណ៏ កើតមាននៅស្រុកខ្មែរ, ចំពោះលោក H. Kissinger ជាលាភផលមួយសំរាប់ ធ្វើអោយមានសន្ទុះថ្មី នូវការចរចាសម្ងាត់ រវាងសហរដ្ឋអាមេរិក និង យួនខាងជើង ស្ដីអំពីការដកទ័ពអាមេរិកាំងចេញពីយៀកណាម។ ការវាយប្រហារ មានកំរិតពេលវេលា និង ចម្ងាយរុលចូល នៃកងទ័ពអាមេរិកាំងនិង យួនខាងត្បូង មកក្នុងស្រុកខ្មែរ ដើម្បី ស្វែងរកកំទិចមូលដ្ឋានយៀកកុងតាំងនៅស្រុកខ្មែរ[11] ក៏ធ្វើឡើងនៅក្នុងយុទ្ធសាស្ត្រ សង្គ្រាមនៅយួនខាងត្បូង ដែលនាំអោយពួកយៀកកុង រុលចូលកាត់តែជ្រៅមកក្នុងទឹកដីខ្មែរ ដើម្បីជៀសវាង ប្រទល់ផ្ទាល់នឹងការវាយលុកនេះមួយរយៈពេល។ នៅពេលនោះ ទឹកដីខ្មែរ ២/៣ ក្លាយជាសមរភូមិយោធា

[11] ប្រយុទ្ធនាការនេះ ចាប់ធ្វើឡើងនៅថ្ងៃទី ៣០ មេសា ឆ្នាំ ១៩៧០ ដល់ថ្ងៃទី ៣០ មិថុនា ចូលមកក្នុងស្រុកខ្មែរ មានកំរិតចម្ងាយតែ ៣០ គីឡូម៉ែត តែប៉ុណ្ណោះ។

របស់យួនកុម្មុយនិស្ត ហើយពួកនេះ ត្រួតត្រា ខេត្តខ្មែរមួយចំនួន គឺ ខេត្ត ក្រចេះ, ស្ទឹងត្រែង, រតនគិរី និង មណ្ឌលគិរី ជាពិសេស ដំបន់ប្រសាទបុរាណនៅខេត្តសៀមរាប។ ទោះបីកងទ័ពជាតិខ្មែរ មាន អាវុធយុទ្ធភ័ណ្ឌតិចតួចយ៉ាងណាក្តី តែអាចតស៊ូស្វិតស្វាញ ទប់ទល់បាន នូការវាយប្រហារនោះ។ ការសន្យា របស់លោក ផាំ វ៉ាន់ដុង និង ជូ អេងឡាយ ជារដ្ឋមន្ត្រីទី១ យួន និង ចិន ចំពោះស្តេចសីហនុថា ទ័ពយួនកុម្មុយនិស្ត អាចវាយកំទិចកងទ័ពជាតិខ្មែរ តែមួយសប្តាហ ដើម្បីយកស្រុកខ្មែរ និង អំណាច មកថ្វាយព្រះអង្គវិញ ក៏ក្លាយជាពាក្យសន្យាខ្យល់តែប៉ុណ្ណោះ។ ជាមួយពេលវេលា ដ៏យូរមួយ គឺ ៥ឆ្នាំ អង្គុយចាំ អំណាច ក៏នាំអោយស្តេចសីហនុ អស់សង្ឃឹមជាស្ថាពរ ថាព្រះអង្គនឹងអាចវិលត្រឡប់ទៅកាន់អំណាចនៅស្រុកខ្មែរវិញ។ តែនៅក្នុងសេចក្តីអស់សង្ឃឹមនេះ ព្រះអង្គនៅមានជានិច្ច ការគំគួនប្រកបដោយ ភាពក្រេវក្រោធនឹងប្រជាពលរដ្ឋខ្មែរ សុខចិត្ត រស់នៅក្នុងទ្រុងកុម្មុយនិស្ត។ រយះពេល៥ឆ្នាំនោះឯងដែលកងទ័ពជាតិខ្មែរ ធ្វើការតស៊ូក្រោមទង់ នៃសាធារណរដ្ឋខ្មែរ ប្រឆាំងនឹងយួនកុម្មុយនិស្ត។ ដោយយល់ឃើញថា

កិច្ចព្រមព្រៀងសន្តិភាព រវាង សហរដ្ឋអាមេរិក និង យួនខាងជើង ដើម្បីបញ្ឈប់សង្គ្រាមនៅយៀកណាម[12] ហើយនៅជំពូកខ្មែរ អាចបើកទ្វាររក ដំណោះស្រាយ នៃជម្លោះរវាងខ្មែរនិងខ្មែរ ដែលមានចិន និង យួនកុម្មុយនិស្ត ជាអ្នកបង្កើត, សាធារណរដ្ឋខ្មែរ សុខចិត្តយល់ព្រមទទួលយកកិច្ចព្រមព្រៀងនោះមកអនុវត្តជាឯកតោភាគី ហើយស្នើដល់ភាគីខ្មែរក្រហម អោយចូលមកចរចា នៅក្នុងស្មារតីរួបរួមជាតិជាតិ ដើម្បីសន្តិភាព សំរាប់ប្រជាពលរដ្ឋខ្មែរ និង ឯកភាពជាតិ ដើម្បីទប់ទល់នឹង គ្រោះថ្នាក់យួនកុម្មុយនិស្ត ដែលវាជាទម្ងន់ នៃបញ្ហាសំរាប់ប្រជាជាតិខ្មែរទៅអនាគត។ តែភាគីខ្មែរក្រហម បដិសេធ នូវសំណើរនេះ នៅក្រោមល្បែង នយោបាយ ចិន និង យួនកុម្មុយនិស្ត ពោលថា ចិន ជាអ្នកហាមមិនអោយខ្មែរ ទទួលស្គាល់ កិច្ចព្រមព្រៀងនេះ ទោះបីខ្លួនជាហត្ថលេខីម្នាក់ក៏ដោយ រីឯយួនវិញ ផ្ញើជាអ្នកបញ្ជោះខ្មែរក្រហម អោយទទួលស្គាល់

[12] កិច្ចព្រមព្រៀងសន្តិភាពនេះ បានចុះហត្ថលេខា រវាងគូប្រតិបក្ស នៅថ្ងៃទី២៧ មករា ឆ្នាំ ១៩៧៣។

កិច្ចព្រមព្រៀង ដើម្បី សំរួលដល់ការទាក់ទងជាមួយអាមេរិកាំងតែប៉ុណ្ណោះ តែតាមពិត ចិន និង យួន ត្រូវការអោយខ្មែរក្រហមនៅក្រៅកិច្ចព្រមព្រៀង ដើម្បីអោយយួន អាចប្រើទឹកដីខ្មែរ ដើម្បីបន្តសង្រ្គាម វាយយួនខាងត្បូង អោយរលំតាមផ្លូវយោធា ព្រោះយួនកុម្មុយនិស្ត មិនចង់ឃើញសភាពការណ៍ នៃសន្និសិទ្ធនៅទីក្រុងសឺណែវ វិលត្រឡប់មកវិញ ពោលថា ត្រូវមាន ការបោះឆ្នោតមួយ នៅយៀកណាមខាងត្បូង ដើម្បី អោយប្រជារាស្ត្រយួនខាងត្បូង ជ្រើសរើសរបបដឹកនាំ។ ក្រោយពីចុះហត្ថលេខារួច យួនគេទុកទ័ពគេជានិច្ចនៅស្រុកខ្មែរ តែក្លែងធ្វើជា ទ័ពរណសេរ្សខ្មែរក្រហមដដែល ហើយ ធ្វើសម្ពាពទៅលើ កងទ័ពសាធារណរដ្ឋ អោយស្ថិតនៅក្នុង ជំហរការពារនៅគ្រប់សមរភូមិ មិនអាចដកទៅជួយគ្នាបាន ដើម្បី បើកឱកាស អោយពួកខ្មែរក្រហម វាយប្រហារទីក្រុងភ្នំពេញ : រដ្ឋធានីភ្នំពេញរលំច្បាស់ជាសាធារណរដ្ឋខ្មែរ រលំជាពុំខាន ព្រោះ រដ្ឋធានី ជានិមិត្តរូប នៃអំណាច នៃរបបដឹកនាំ។ ត្រូវដឹងថា ទោះបីយួន បន្តធ្វើសង្រ្គាមនៅស្រុកខ្មែរ តែលើកនេះមាន ការចូលរួម ជាសកម្ម នៃទ័ពខ្មែរក្រហមនៅក្នុងសមរភូមិ

ដើម្បី បញ្ឆោត មតិអន្តរជាតិថា សង្គ្រាមនៅស្រុកខ្មែរ ចាប់ពីឆ្នាំ ១៩៧៣ ជាសង្គ្រាមស៊ីវិល។ ដើម្បីជៀសវាង សង្គ្រាមស៊ីវិលនេះ លោក អ៊ិន តាំ ត្រូវបានតែងតាំងជា រដ្ឋមន្ត្រីទី១ នៅថ្ងៃទី១០ ឧសភា ឆ្នាំ ១៩៧៣ ដើម្បី ស្វែងរកទំនាក់ទំនងផ្ទាល់ ជាមួយសម្តេច សីហនុ។ ត្រូវដឹងដែរថា នៅថ្ងៃនោះដែរ សភាអាមេរិកាំង បានបោះឆ្នោត ហាមមិនអោយ កងទ័ពអាកាសអាមេរិកាំង ធ្វើអន្តរគមន៏នៅស្រុកខ្មែរ។ ដើម្បី បង្ហាញ នូវទឹកចិត្តចំហររកដំណោះស្រាយ, នៅថ្ងៃទីថ្ងៃទី៣១ ឧសភា រដ្ឋាភិបាលលោក អ៊ិន តាំ បានដោះលែង បុត្រា-បុត្រី ៥នាក់ និង អ្នកជំនិត ៤នាក់ របស់ស្តេចសីហនុ ហើយអ្នកទាំងនោះ អាចចាកចេញពីស្រុកខ្មែរបានដោយសេរី។ ថ្ងៃទី២០ មិថុនា ក៏មានការដោះលែងលោក អ៊ុំ ម៉ាណូរិន ជាបងប្រុសអ្នកម្នាងម្និច និង សហការីទាំងអស់ របស់ស្តេចសីហនុ ដែលបានចាប់ឃុំឃាំងតាំងពីថ្ងៃទី ១៨ មិនា ឆ្នាំ ១៩៧០ មកម្លេះ ហើយអ្នកទាំងនោះ អាចចាកចេញពី ស្រុកខ្មែរបានដោយសេរី។ គួររំឭកថា លោក អ៊ិន តាំ លោកតែងតែយក គោលការណ៏ចរចាជាមួយស្តេចសីហនុ ជាខ្សែនាយក នៃនយោបាយ របស់

លោក ដូចយ៉ាង នៅពេលដែលលោក ឈរជាបេក្ខជនប្រធានាធិបតី ប្រឆាំងនឹងលោក លន់ នល់ លោក បានដាក់ចំណុចសំខាន់នេះ នៅក្នុងកម្មវិធីនយោបាយ របស់លោក ពោលថា បើលោក ត្រូវប្រជាពលរដ្ឋ ជ្រើសរើសយករូបលោកជាប្រធានាធិបតី លោកនឹងធ្វើការចរចាជាមួយស្តេចសីហនុជាបន្ទាន់[13]។

គួរលើកយកចំណុចសំខាន់នេះ មកបកស្រាយ ជាជម្រៅដើម្បី យល់អំពី គំនិតនយោបាយ នៃ ពួក នយជនចម (les principaux politiques) នៃរបបសាធារណរដ្ឋ នៅក្នុងសង្គ្រាម។ តាំងពីសង្គ្រាមកើតឡើងភ្លាម វាមានបែងចែកជាក្រុមនយោបាយ មួយចំនួន មានគំនិតផ្ទុយគ្នា។ ក្រុម

---

13 យុទ្ធនាការ នៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ធ្វើឡើងនៅក្នុងខែឧសភាឆ្នាំ ១៩៧២។ មានបេក្ខជនបីនាក់ គឺ លោក លន់ នល់, អ៊ិន តាំង និង កែវ អាន។ ហើយលោក លន់ នល់ ត្រូវបានជាប់ឆ្នោតជាប្រធានាធិបតីនៅថ្ងៃទី៤ មិថុនា។ លោក អ៊ិន តាំ ទទួលបានសម្លេងច្រើនជាងគេនៅទីក្រុងភ្នំពេញ។ ចំណែកលោក កែវ អាន បដិសេធ លទ្ធផល នៃការបោះឆ្នោត ដោយចោទប្រកាន់ថា ជាលទ្ធផលក្លែងក្លាយ។ សម្លេងឆ្នោត៖ លន់ នល់ ៥៩,៩៣%, អ៊ិន តាំ ២៤,៤៤%, កែវ អាន ២០,៦១%។

ទាំងឡាយនោះគឺ ក្រុមទ្រង់សិរិមត:, ក្រុមលោក អ៊ិន តាំង និង ក្រុមលោក ហង្ស ធុនហាក់។ ចំណែកលោក លន់ នល់ វិញ ហាក់បីដូចលោក ឬក៏ ដាក់ខ្លួនលោក នៅពីលើក្រុមទាំងឡាយនោះ ឬក៏ ក្រុមទាំងនោះ ទុកលោក អោយនៅក្រៅ សែវៀននយោបាយ។ បំណែកនេះ បណ្តាលអោយមានកើតមាន គណបក្សនយោបាយធំៗបី គឺ : គណបក្សសាធារណរដ្ឋ (ទ្រង់សិរិមត:), ប្រជាធិបតេយ្យ (លោក អ៊ិន តាំ) និង សង្គមសាធារណរដ្ឋ (លោក ហង្ស ធុនហាក់-លន់ នន់)។ នៅពេលបោះឆ្នោតនីតិបញ្ញាតិ នៅខែកក្កដា ឆ្នាំ ១៩៧២, គណបក្សសាធារណរដ្ឋ និង ប្រជាធិបតេយ្យ ធ្វើពហិការ ដោយយល់ឃើញថា សភាពការណ៍នយោបាយ និងយោធា មិនអាចនឹង រៀបចំការបោះឆ្នោតអោយបានត្រឹមត្រូវនោះឡើយ។ ដូច្នេះ មានតែគណបក្ស សង្គមសាធារណរដ្ឋ និង គណបក្សតូចមួយ ឈ្មោះ គណបក្សប្រជារាស្ត្រ ដែលគេដឹងថាជាគណបក្សបង្កើតឡើងដោយ ឧត្តមសេនីយ លន់ នន់ ជាប្អូនលោក លន់ នល់ ចូលរួមបោះឆ្នោត នៅពេលនោះ។

ភ្លើងសង្គ្រាមនៅស្រុកខ្មែរ កាន់តែមានសភាពសាហាវឡើង ព្រោះពួកយួនកុម្មុយនិស្ត គេមានកតិកា វាយប្រលំរបបសាធារណរដ្ឋអោយបានជាដាច់ខាត។ នៅក្នុងសមរភូមិ ទាហ៊ានយួន មិនរញ៉េរា អនុវត្ត នូវគោលវិធីភេរវកម្មកំណាច ទៅលើប្រជារាស្ត្រខ្មែរស្លូតត្រង់ និង ព្រះសង្ឃ។ នៅគ្រប់សមរភូមិ ពួកយៀកកុង តែងតែយកប្រជារាស្ត្រខ្មែរធ្វើជាខែល និង យកវត្តអារាម វិហារកាតូលិក ធ្វើជាជម្រកពួនបាច់កងទ័ពជាតិខ្មែរ ហើយនៅពេលណា មានការវាយប្រហារតបពីទាហ៊ានខ្មែរ ពួកនោះតែងតែថតរូប ផ្ញើរទៅការសែតធំៗនៅក្នុងពិភពលោកអោយចុះផ្សាយថា កងទ័ពខ្មែរ សាហាវណាស់ ហ៊ានបាច់ប្រជារាស្ត្រខ្លួនឯង និងបាញ់ប្លោង កំទិចវត្តអារាម និង វិហារកាតូលិក ដែលនាំអោយមតិអន្តរជាតិ និង មជ្ឈដ្ឋាន នៃសាសានាកាតូលិកមានប្រតិកម្មអវិជ្ជមាន មកលើសាធារណរដ្ឋខ្មែរ។ ត្រូវដឹងទៀតថា នៅពេលណាពួកយៀកកុង ចូលកាន់កាប់ភូមិណាមួយ ពួកវាតែងតែ ធ្វើការកាប់សម្លាប់រង្គាលទាំងព្រះសង្ឃ មនុស្សចាស់ ស្ត្រី និង កុមារ គ្មានត្រាប្រណី។ លោក អ៊ុន តាំ ដែលជា អតីតសិស្សនាយទាហ៊ានបំរុង ជំនាន់ទី៤

បានស្ម័គ្រត្រឡប់ ចូលបំរើកងទ័ព ជាឧត្តមសេនីយត្រី ទទួលមុខដំណែង ជាមេបញ្ជាការភូមិភាគយោធាទី១ និង ជាអភិបាលខេត្តកំពង់ចាម ហើយនៅពេលដែលរៀបនឹង ឡើងឧទ្ធម្ភាគចក្រទៅកាន់សមរភូមិ លោកបានឆ្លើយនឹង សំនួរអ្នកកាសែតបរទេសម្នាក់ថា : « លោកសួរខ្ញុំថា តើខ្ញុំ មានសេចក្តីក្លាហានដែរឬទេ ? ខ្ញុំសូមជំរាបលោកថា ការ តស៊ូខ្មែរប្រឆាំងនឹងយួនយៀកកុង និង យួនយៀកម៉ិញ, ជនខ្មែរម្នាក់ៗ មិនចាំបាច់មានសេចក្តីក្លាហាននោះទេ ព្រោះថា ការតស៊ូនេះ វាជា សភាវគតិ របស់ជនខ្មែរតែម្តង ...។ » ពាក់ នូវសភាវគតិនេះឯង ដែលយុវជនខ្មែររាប់ម៉ឺន នាក់ ជំនាន់នោះ ស្ម័គ្រចិត្ត ចូលធ្វើទាហ៊ាន ហើយ លាពុក ម៉ែ ទៅកាន់សមរភូមិ បូជាជីវិតខ្លួន ចំនួនច្រើនក្រៃលែង នៅចំពោះមុខការវាយប្រហារដ៏កាចសាហាវ នៃខ្មាំងជាតិ។ បើគ្មានពលិកម្មខ្ពង់ខ្ពស់ និង ការតស៊ូស្វិតស្វាញនេះទេ ប្រហែលជាពេលនោះ យួនយៀកកុង គេវាយយកស្រុកខ្មែរ បានងាយស្រួល ហើយតែងតាំងក្រុមអាយ៉ងគេ, នៅក្នុង ចំណោមនោះ វាគ្មាន ស្តេចសីហនុ និង ពួកមេដឹកនាំខ្មែរ ក្រហមមួយចំនួន, ចដឹកនាំស្រុកខ្មែរ ដូចគ្នានឹង ថ្ងៃទី៧

មករា ឆ្នាំ ១៩៧៩ នេះឯង។ ហើយចិនក្រហម នឹងបិទភ្នែក រួចផ្អឹប ស្តេចសីហនុ ទុកនៅក្នុងវិមាននៅទីក្រុងប៉េកាំង រួចបន្តជួយយួនកុម្មុយនិស្តជាមិត្ត ច្បាំងនឹងអាមេរិកាំង និង យួនខាងត្បូង[14] ព្រោះប៉េកាំង មិនអាចបោះបង់យួនកុម្មុយនិស្ត ដ្បិតវាជា កតព្វកិច្ចរួមគ្នា រវាងបក្សកុម្មុយនិស្តនៅលើសាកលលោក។

ត្រឡប់មកនិយាយអំពី គោលនយោបាយ នៃក្រុមទាំងបីពាក់ព័ន្ធនឹងសង្គ្រាម។ លើសភាពក្រៅ លើចំណុចនេះ ក្រុមទាំងនោះ ជៀសវាង លើកយកគំនិតខុសគ្នា មកពិភាក្សាជាសាធារណ:, មូលហេតុ វាងាយស្រួលនឹងយល់ណាស់ គឺ

---

[14] ត្រូវដឹងថា នៅពេលដែលលោក លន់ នល់ ជួបទូតចិន ក្រោយពីសភាជាតិបោះឆ្នោតទម្លាក់ស្តេចសីហនុពីដំណែង ចិនគេស្នើដល់លោក លន់ នល់ អោយបន្តជួយយៀកកុងដូចជម្មតា ឯចំណែកបុគ្គលសីហនុ ចិនគេធានាថាគេអាចធ្វើមិនអោយព្រះអង្គរំខានបាន ដល់របបថ្មីនៅស្រុកខ្មែរ។ តែនៅពេលនោះ លោក លន់ នល់ លោក បានបដិសេធ នូវសំណើរនោះ ដែលនាំតំណាងចិនខឹងណាស់ រួចកំញើញថា បើលោកបដិសេធដូច្នេះ លោកនឹងរងគ្រោះនឹងសង្គ្រាមកាចសាហាវ ដែលមានចិនជាអ្នកគាំទ្រពេញទំហឹង។

ជៀសវាង កុំអោយ ប៉ះពាល់ដល់ សិទ្ធិពល នៃខ្សែនាយក នៃសង្គ្រាមតស៊ូ, តែ សភាពក្នុងវិញ ជម្លោះ វាមានពិត។

## ១. គណបក្សសាធារណរដ្ឋ

ក្រុមនេះ យល់ឃើញថា ត្រូវមានជាដាច់ខាត នូវដំណោះស្រាយ នយោបាយ-យោធា។ វត្ថុធាតុទាំងពីរនេះ ជាលក្ខខណ្ឌចាំបាច់ សំរាប់រកដំណោះស្រាយ ជាមួយភាគីខ្មែរម្ខាងទៀត ដើម្បីរួមគ្នា តស៊ូប្រឆាំងនឹងយួនកុម្មុយនិស្ត។ បើគ្មាន កម្លាំងយោធាខ្លាំងនៅលើសមរភូមិ គឺវាគ្មានកម្លាំងនយោបាយ សំរាប់ចរចា, តែបើគ្មានគោលការណ៍នយោបាយច្បាស់លាស់ និង អង្គការនយោបាយ សំរាប់ដឹកនាំសង្គ្រាម ក៏វាមិនអាចបង្កើត នូវលក្ខខណ្ឌ ចាំបាច់ ដើម្បី ពង្រឹង នូវកម្លាំងយោធាបានដែរ។ គ្រប់ការស្វែងរកការចរចា គ្មានលក្ខខណ្ឌទាំពីរនេះ គឺជាការសុំចុំចាញ់តែប៉ុណ្ណោះ។

## ២. គណបក្ស ប្រជាធិបតេយ្យ

ក្រុមនេះ យល់ឃើញថា សង្គ្រាមនៅស្រុកខ្មែរ គ្មានដំណោះស្រាយតាមផ្លូវយោធា រវាង សាធារណរដ្ឋខ្មែរ នឹង ខ្មែរម្ខាងទៀត ជាដាច់ខាត។ ដូច្នេះ ត្រូវចាំបាច់ រកដំណោះស្រាយ

ជាមួយស្តេចសីហនុ តាមសន្តិវិធី។ ការស្ម័គ្រចិត្ត ជួយខ្មែរ នៃសហរដ្ឋអាមេរិកាំង នៅក្នុងកំរិតទាប នាំអោយលោក អ៊ិន តាំ ពង្រឹងគំនិតនេះ ក្លាយជាជំនឿស៊ប់ របស់គាត់ រហូតលោក យកជំនឿនេះ មកបញ្ចូល នៅក្នុងកម្មវិធី នយោបាយ របស់គណបក្សប្រជាធិបេតយ្យ។ ឃ្លាដែល លោកតែងតែនិយាយជារូបមន្ត នៅពេលប្រជុំ ជាសាធារ ណៈម្តងៗ គឺថា : គ្មានដំណោះស្រាយណាមួយនៅស្រុកខ្មែរ ដោយគ្មានសម្តេចសីហនុ ចូលរួមនោះឡើយ នៅចំពោះ មុខគ្រោះថ្នាក់យួនរួមតែមួយ នៅក្រោមការដឹកនាំ នៃ បក្សកុម្មុយនិស្តយួន។ ត្រូវដឹងថាលោក អ៊ិន តាំ លោក បានស្ដីរំឭកអាមេរិកាំងថាជាការច្រឡំមួយ ដែលអនុញ្ញាត អោយកងទ័ពយួនខាងត្បូង ចូលមក ធ្វើប្រតិបត្តការ សឹករួមជាមួយកងទ័ពអាមេរិកាំង នៅថ្ងៃទី ៣០ មេសា ឆ្នាំ ១៩៧០ ដល់ថ្ងៃទី ៣០ មិថុនា ចូលមកក្នុងស្រុកខ្មែរ មានកំ រិតចម្ងាយតែ ៣០ គីឡូម៉ែត តែប៉ុណ្ណោះ។ វត្តមាន នៃទ័ព យួនខាងត្បូងនៅពេលនោះ វានាំអោយ រដ្ឋាភិបាលខ្មែរ ពិបាក ពន្យល់ដល់ប្រជារាស្ត្រខ្មែរ ដែលកំពុងប្រឆាំងនឹង វត្តមាន យួនយៀកកុងនៅស្រុកខ្មែរ, ស្រាប់តែឃើញទា

ហ៊ានយួនខាងត្បូង ដើរចូលស្រុកខ្មែរតាមសេរី។ ចំពោះលោក អ៊ិន តាំ លោក សួរជាសំនួរថា តើអ្វីទៅ ដែលជា ការសមហេតុសមផល សំរាប់ប្រជាពលរដ្ឋខ្មែរ នៅពេលនោះ[15] ដែលជាអ្នករងគ្រោះ ព្រោះនៅក្នុងគំនិតរាស្ត្រខ្មែរ គឺគ្មានយួនពីរទេ ពោលថា យួនក្រហម និង យួនសេរី គឺ ជាយួនតែមួយ។

## ៣. គណបក្សសង្គមសាធារណរដ្ឋ

គួរកត់សំគាល់ថា ក្រុមនេះ មានប្រភពចេញពីពួកខ្មែរឥស្សរៈ ឬ ខ្មែរសេរី ដឹកនាំដោយលោក សឺង ង៉ុកថាញ់ ហើយគួររំឭកដែរថា លោក សឺង ង៉ុក ថាញ់ កាលសម័យតស៊ូប្រឆាំងនឹងបារាំង លោក មានទំនាក់ទំនង ជិតស្និតជាមួយពួកយួនយៀកម៉ិញ។ លោក ហង្ស ធុនហាក់ កាលនៅជាយុវជន ធ្លាប់បានរត់ចូលព្រៃ ទៅរស់នៅភ្នំដងរែករួមតស៊ូជាមួយលោក សឺង ង៉ុកថាញ់ ប្រឆាំងនឹងស្តេចសីហ

---

[15] ត្រូវដឹងថា នៅពេលនោះ រដ្ឋាភិបាលខ្មែរ តម្រូវធ្វើសេចក្តីថ្លែងការ ជាផ្លូវ បន្ទោស ដល់ ប្រតិបត្តិការសឹក អាមេរិកាំង-យួនខាងត្បូង ចូលមកក្នុងដែនដីខ្មែរ ដោយគ្មានជូនដំណឹងជាមុន។

នុ ក្នុងឋានៈលោកជា អ្នកអត្ថាធិប្បាយនយោបាយ នៃ វិទ្យុតស៊ូក្នុងព្រៃ។ ក្រោយពីស្រុកបានឯករាជ្យ លោក វិលត្រ ឡប់ចូលមករស់នៅទីក្រុងភ្នំពេញវិញ តែនៅរក្សាជានិច្ច នៅក្នុងចិត្ត នូវអណ្តាតភ្លើងបដិវត្តន៍ និង រក្សាក្រុមតស៊ូ ពួកភ្នំដងរែកជាក្រុមសម្ងំដេក ហើយនិងមាន ទំនាក់ ទំនង ជានិច្ចជាមួយពួកខ្មែរយៀកមិញ និង ខ្មែរសេរី ដែល ពួនលាក់ខ្លួន ធ្វើសកម្មភាពនយោបាយ នៅស្រុកខ្មែរ។ ក្រោយពីទំលាក់ស្តេចសីហនុ ក្រុមនេះ មានទំនាក់ទំនង ពិសេស ជាមួយ ឧត្តមសេនីយ លន់ នន់ ដើម្បី ស្វែងរក នូវ ឥទ្ធិពលនយោបាយ ទៅលើលោក លន់ នល់។ តាំងពីដំបូល ទីមក ក្រុមនេះ ហាក់បីដូចជាមានគោលបំណង ដើរតួរជា កំពែង សំរាប់ការពាររបបសាធារណរដ្ឋ ដែលលោក លន់ ន ន់ យកធ្វើជាអាវុធនយោបាយ សំរាប់ប្រឆាំង នឹងទ្រង់សិរិ មតៈ និងការវិលត្រឡប់ នៃរបបរាជានិយម។ ក្រុមនេះ មិនសូវយកចិត្តទុកដាក់នឹងសង្គ្រាម ព្រោះយល់ឃើញថា កិច្ចការយោធា ជាកិច្ចការ របស់លោក លន់ នល់ ហើយនរៈ នេះ (celui-ci) អាចក្តាប់វាបានក្នុងឋានៈលោកជា មគ្គ ទេសយោធា ដែលគ្មាននរណាប្រកែកបាន។ តែក្រុមនេះ

មានទ្រឹស្តីមួយ ទៅលើការបញ្ចប់ នៃសង្គ្រាមទៅថ្ងៃមុខ គឺពួកគេយល់ឃើញថា គេនឹងអាច ធ្វើសហការណ៍ជាមួយពួកខ្មែរយៀកម៉ិញ និង ក្រុមខ្មែរក្រហមមួយចំនួន[16] ដែលកំពុងតស៊ូនៅក្នុងព្រៃ។ ក្រុមនេះឯង ដែលបានស្នើដល់លោក លន់ នល់ អោយជ្រើសយកលោក សឺង ង៉ុកថាញ់ ជារដ្ឋមន្ត្រីទី១ បន្ទាប់ពីលោក លន់ នល់ ប្រកាសខ្លួនដោយខ្លួនឯង ជាប្រធានាធិបតី ក្រោយពីលោក ចេង ហេង ប្រកាសលាលែងពីតំណែងប្រមុខរដ្ឋ។ ចំពោះពួកនេះ ការជ្រើសរើសនេះ ជានិមិត្តរូបខ្លាំងណាស់ សំរាប់ របបសាធារណរដ្ឋខ្មែរ ព្រោះលោក សឺង ង៉ុកថាញ់ ជានិមិត្តរូបនៃគំនិតសាធារណរដ្ឋជាប្រវត្តិសាស្ត្រ[17] និង ការផ្តាច់ជាស្ថាពរ ពីរបបចាស់។ ចាប់ពីខែមីនា ឆ្នាំ ១៩៧២ រហូត ដល់ខែ មេសា ឆ្នាំ ១៩៧៣ ពួកលោក ហង្ស ធុនហាក់ ជាអ្នក

---

[16] ត្រូវដឹងថានៅពេលនោះពួកខ្មែរក្រហម គ្មានឯកភាពយោធាទេ។ ដំបន់និមួយៗ សុទ្ធតែមានមេរៀងៗខ្លួន ហើយមេនិមួយៗសុទ្ធតែតាំងខ្លួនឯក ជាមេម្តេចមុខនៅក្នុងដំបន់ខ្លួនត្រួតត្រា។

[17] លោក សឺង ង៉ុកថាញ់ ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៅថ្ងៃទី២១ មីនា ឆ្នាំ ១៩៧២។

ដឹកនាំផ្ដាច់មុខនយោបាយនៅស្រុកខ្មែរ។ បន្ទាប់ពីលោក សឺង ង៉ុកថាញ់ លាលែងពីដំណែងរដ្ឋមន្ត្រីទី នៅថ្ងៃទី១៤ តុលា ឆ្នាំ ១៩៧២ ដោយលោក យល់ឃើញថា បេសកកម្ម របស់លោកបានចប់សព្វគ្រប់ គឺ: ការរៀបចំបោះឆ្នោត ជ្រើសរើស ប្រធានាធិបតី, បោះឆ្នោតជ្រើសរើស តំណាងរាស្ត្រ, សមាជិកព្រឹទ្ធសភា និង ការទទួលស្គាល់ នៃរបប សាធារណរដ្ឋខ្មែរ ជាតំណាង នៃប្រជាពលរដ្ឋខ្មែរ ពីសំណាក់ អង្គការសហប្រជាជាតិ នៅថ្ងៃទី១២ តុលា ឆ្នាំ ១៩៧២[18]។ លោក លន់ នល់ បានតែងតាំងលោក ហង្ស ធុនហាក់ ជា រដ្ឋមន្ត្រីទី១ ជំនួសលោក សឺង ង៉ុកថាញ់។ គួររំឭកដែរថា រដ្ឋាភិបាល ដឹកនាំដោយលោក សឺង ង៉ុកថាញ់ ជួបប្រទះ នឹងការបះបោរ នៃពួកនិស្សិត ប្រឆាំងនឹងវិធានការ របស់ លោក សឺង ង៉ុកថាញ់ ចាប់និស្សិត ឈ្មោះ កុយ ប៊ុច ព្រោះនរៈនេះ បានជេរប្រមាទលោក លន់ នល់ ថាជាជនផ្ដាច់ការ

18 សភាអង្គការសហប្រជាជាតិ បានបោះឆ្នោតទទួលស្គាល់របប សាធារណរដ្ឋខ្មែរ ជារបបតំណាងប្រជាពលរដ្ឋខ្មែរ, មានសម្លេង គាំទ្រ ១៣២ ប្រទេស និង សម្លេងប្រឆាំង ១១ ប្រទេស។

នៅក្នុងកម្មវិធីទូរទស្សន៍ ស្ដីអំពីខ្លឹមសារ នៃរដ្ឋធម្មនុញ្ញ។ និស្សិតនេះ បានរត់ចូលទៅពួននៅក្នុង មហាវិទ្យាល័យនីតិសាស្ត្រ ហើយមានការការពារ ពីសំណាក់និស្សិតជាច្រើន នៅចំពោះមុខកងអាវុធហត្ថ ដែល បានមកលោមព័ទ្ធមហាវិទ្យាល័យ ក្នុងគោលបំណងចាប់និស្សិត កុយ ប៊ុច។ ការប្រទល់មុខគ្នារវាង និស្សិត និង កងអាវុធហត្ថ បណ្ដាលអោយមានផ្ទុះអាវុធ នាំអោយនិស្សិតមួយចំនួនមានរបួស ហើយពេលនោះ ពួកនិស្សិត បានចោទប្រកាន់ថា មានរហូតដល់ស្លាប់ផង តែកងអាវុធហត្ថ យកសពទៅលាក់។ ក្រោយពីមានកើតឧប្បត្តិហេតុនេះ លោក ស៊ីង ង៉ុកថាញ់ បានបង្គាប់បញ្ជា អោយបិទទ្វារ មហាវិទ្យាល័យទាំងឡាយមួយរយៈ[19]។ ចំណែក លោក ហង្ស ធុនហាក់ វិញ

---

19 ការពិតនៅពេលនោះ គ្មាននិស្សិតណាមួយ ស្លាប់នោះឡើយ។ ហើយពួក ដែលអ្នកមានរបួស ក៏មិនមែនជារបួស ដោយគ្រាប់កាំភ្លើងនោះដែរ គឺមកពីការវាយតប់គ្នាខ្លះ រវាងនិស្សិត និង កងអាវុធហត្ថ។ ការវាយតប់គ្នានេះឯង ដែលតម្រូវអោយកងអាវុធហត្ថបាច់កាំភ្លើងទៅលើដើម្បីបំបែកហ្វូងនិស្សិត ដែលចេះតែ រុញច្រានខ្លាំងឡើងៗ មកលើពួកកងអាវុធហត្ថ អោយចេញពីមាត់ទ្វារមហាវិទ្យាល័យ។ តែឧប្បត្តិហេតុ ពង្វាត រហូតក្លាយទៅជាវិបត្តិ

នយោបាយសំខាន់ រវាងនិស្សិត នឹងរដ្ឋាភិបាលលោក សឹង ង៉ុកថាញ់ ដែលនាំអោយយុវជន លែងមានសេចក្តីទុកចិត្តទៅលើបុគ្គល សឹង ង៉ុកថាញ់ តែម្តង។ ដើម្បី ជួយលោក សឹង ង៉ុកថាញ់ ពួកលោក លន់ នន់ ដែលជាសមាជិកម្នាក់នៅក្នុងរដ្ឋាភិបាល បានបង្គាប់បញ្ជាយុវជនមួយក្រុម ស្ម័គ្របក្សនឹងខ្លួន ចែក និង បិទ ខិត្តប័ណ្ណនៅវិមានឯករាជ្យ ចោទប្រកាន់ថា ការផ្ទុះអាវុធនោះ ជាស្នាដៃរបស់ពួកទ្រង់សិរិមតៈ ព្រោះមេបញ្ជាការដែលបង្គាប់បញ្ជាអោយបាញ់នោះ គឺលោក វរសេនីយទោ ឧប គឹមអួន ដែលជាប្អូនលោក ឧប គឹមអាង នៅពេលនោះ លោកជាអគ្គលេខាធិការ នៃគណបក្សសាធារណរដ្ឋ ដែលជាគណបក្សដឹកនាំដោយ ទ្រង់សិរិមតៈ។ ការពិត វត្តមានលោក ឧប គឹមអួន នៅពេលនោះ គ្រាន់តែជាអ្នកមកសង្កេតមើលស្ថានភាព តាមបញ្ជា របស់លោក ឧត្តមសេនីយ អគ្គមេបញ្ជាការកងអាវុធហត្ថតែប៉ុណ្ណោះ ដូច្នេះ កងអាវុធហត្ថនៅមុខមហាវិទ្យាល័យ មិននៅក្រោមបញ្ជាការលោកនោះទេ តែជា ចៃដន្យមួយ នៅពេលដែលលោកមកដល់ទីកន្លែងកើតហេតុនោះភ្លាម វាមានផ្ទុះអាវុធភ្លាមដែរ។ ចៃដន្យនេះឯង ដែលពួកលោក លន់ នន់ យកទៅកែឆ្នៃដើម្បីទាញយកជាប្រយោជន៍នយោបាយ តែក្រោយពីមានការធ្វើអង្កេត វាគ្មានឃើញវត្ថុធាតុណាមួយ ដែលបង្ហាញពិតថា លោក ឧប គឹមអួន ជាអ្នកបង្គាប់បញ្ជាអោយបាញ់នោះឡើយ។ លោក សឹង ង៉ុកថាញ់ បានវិលត្រឡប់ទៅរសនៅស្រុកយួនខាងត្បូងវិញ នៅខែកក្កដា ឆ្នាំ ១៩៧៣ ហើយលោកឈប់មានទំនាក់ទំនងជាមួយលោក លន់ នល់ តាំងពីពេលនោះមក។ នៅពេលដែលយួនខាងជើងទទួលបានជ័យជំនះ ពួកយួនបានមកចាប់លោកពីផ្ទះ ហើយក៏បាត់ ដំណឹងលោក រហូតពីពេលនោះមក។

ក្នុងរយៈពេលដឹកនាំ រដ្ឋាភិបាល លោកជួបប្រទះនឹងវិបត្តិធំពីរ : ការផ្ទុះអាវុធ នៅថ្ងៃទី១៧ មីនា ឆ្នាំ ១៩៧៣ នៅវេលាព្រឹកព្រលឹម នៅក្នុងសាលាគរុកោសល្យ ដែលបណ្តាលអោយមានស្លាប់មនុស្សពីរនាក់ និង របួសមួយនាក់[20] និង នៅពេលរសៀល លោក អនុសេនីយទោ នៃកងទ័ពអាកាសចរណ៍ អ្នកបើកយន្តហោះ T28 ឈ្មោះ សូ ផូត្រា ដែលជាកូនប្រសារ របស់ស្តេចសីហនុ បានទម្លាក់គ្រាប់បែកពីរគ្រាប់ទៅលើវិមានចំការមន ដែលនាំអោយឆេះ បន្ទាយកងអង្គរក្សលោកប្រធានាធិបតី តែពេលនោះ លោក លន់ នល់ មិនបានទទួលគ្រោះថ្នាក់នោះទេ។ ក្រុមលោក ហង្ស ធុនហាក់ និង លន់ នន់ មានបំណងចង់ទម្លាក់កំហុសនេះ ទៅលើទ្រង់សិរិមតៈ ថាជា អ្នកនៅពី

---

[20] នៅពេលនោះមានការបះបោរពីសំណាក់ពួកគ្រូបង្រៀន ដែលមិនបានទទួលប្រាក់ខែ ហើយកាន់កាប់សាលាគរុកោសល្យ ដោយមានចាប់មន្ត្រីជាន់ខ្ពស់ នៃក្រសួងអប់រំជាតិ ជាចំណាត់ខ្មាំង អស់រយៈពេលច្រើនថ្ងៃមកហើយ។ នៅថ្ងៃនោះ នៅពេលព្រលឹម មានកងពិសេសមួយ លបចូលទៅរំដោះ ចំណាត់ខ្មាំង ដែលនាំអោយមានផ្ទុះអាវុធ ព្រោះត្រូវដឹងថានៅសាលានោះ មាននិស្សិតប្រដាប់អាវុធ យាមកាម។

ក្រោយព្រឹត្តិការណ៍ទាំងពីរនេះ។ លោក ហង្ស ធុនហាក់ បានស្នើដល់រដ្ឋសភាព សូមចាប់ ព្រះរាជវង្សានុវង្ស មួយចំនួន[21] អោយតុលាការសឹកជំនុំជំរះ តែសំណើរនេះ ត្រូវបានរដ្ឋសភាច្រានចោល ដែលនាំឲលោក លាលែងពីតំណែងរដ្ឋមន្ត្រីទី១។ ដើម្បី បន្ធូរស្ថានការតឹងរឹង រវាងក្រុមទ្រង់សិរិមតៈ និង ហង្ស ធុនហាក់-លន់ នន់, លោក លន់ នល់ បានស្នើអោយលោក ឧប គីមអាង[22] ធ្វើជារដ្ឋ

---

[21] ក្នុងចំណោមនោះ មានឈ្មោះទ្រង់សិរិមតៈ។

[22] លោក ឧប គីមអាង ជាឪពុក របស់ខ្ញុំ, ហើយខ្ញុំលើកជីវប្រវត្តិជាសង្ខេប របស់លោក មកនិយាយនៅទីនេះ ព្រោះ សម័យនេះ គេមិនសូវស្គាល់ឈ្មោះលោកទេ ដ្បិតលោក មិនមែន ឥស្សរជនល្បីឈ្មោះអ្វីនោះឡើយ នៅក្នុងព្រឹត្តិការណ៍នយោបាយធំរបស់ជាតិ។ លោក ជា នយជន (le politique) មួយ ជំនិតនឹងលោក លន់ នល់ ផង និង ទ្រង់សិរិមតៈផង។ លោក កើតនៅថ្ងៃទី ២៨ កុម្ភៈ ឆ្នាំ ១៩២២ នៅស្រុកក្រចេស ក្នុងខេត្ត តាកែវ។ ជាអតីតសិស្សវិទ្យាល័យស៊ីសុវត្ថ ហើយប្រឡងជាប់ ចូលរៀនសាលារដ្ឋបាល។ ក្រោយពីចេញពីសាលាមុនស្រុកខ្មែរទទួលបានឯករាជ្យ លោក បានទទួលមុខដំណែងជាច្រើននៅក្នុងរាជការខ្មែរ ដូចយ៉ាងជាបាឡាត់ខេត្ត (adjoint du gouverneur) ចៅហ្វាយស្រុកមួយចំនួន។ នៅទស្សវត្សរ៍ ៥០ លោកបានចូលរួមក្នុងឆាកនយោបាយ ដោយចូលធ្វើជាសមាជិក នៃគណបក្ស បុនក្ការខ្មែរ បង្កើតឡើង លោក លន់ នល់ និង ទ្រង់សិរិមតៈ។ ក្រោយពីស្រុកខ្មែរបានឯករាជ្យ នៅសម័យ

មន្ត្រីទី១ ដើម្បី រៀបចំបង្កើត នូវរដ្ឋាភិបាលរួបរួមជាតិមួយ ព្រោះ លោកជា នយជនស្ថិតនៅកណ្តាល នៃចរន្ត នយោបាយទាំងឡាយ, តែលោកប្រកែក ដោយលើក នូវ មូលហេតុថាលោក គ្មានលទ្ធភាពនឹងអាចរៀបចំបង្កើត នូវរដ្ឋាភិបាលបាននោះឡើយ។ បន្ទាប់មកលោក លន់ នល់

---

សង្គមរាស្ត្រនិយម លោក បានតែងតាំងជាច្រើនដងជាអភិបាល ខេត្ត, ស្ទឹងត្រែង, ព្រៃវែង និង កំពង់ចាម។ ក្រោយមក លោកបាន ជួបឆ្នោតជាតំណាងរាស្ត្រ បន្តអាណត្តិ រហូតមកដល់ឆ្នាំ ១៩៧២ ហើយនៅក្នុងរយៈពេលនោះ លោក ធ្លាប់ជាប់ឆ្នោត ជាអនុ ប្រធានរដ្ឋសភា និង ធ្លាប់ធ្វើជាប្រធាន គណកម្មការ កិច្ចការ សង្គមកិច្ច។ នៅពេលរយៈពេលនោះដែរ លោក ត្រូវតែងតាំងជា ច្រើនលើក ជាសមាជិករាជរដ្ឋាភិបាល: រដ្ឋលេខាធិការក្រសួង មហាផ្ទៃ ដែលមានលោក សែន កុសល ជានាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងការពារជាតិ ដែលមានលោក លន់ នល់ ជានាយករដ្ឋមន្ត្រី ហើយនៅក្នុង រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ដឹកនាំដោយមាន លោក លន់ នល់ ក្នុងឋានៈ ជា ឧបនាយករដ្ឋមន្ត្រីទី៣ ទទួលបន្ទុក ក្រសួង ហេរញ្ញវត្ថុ និង សេដ្ឋកិច្ចជាតិ។ នៅក្នុងរបបសាធារណរដ្ឋ ខ្មែរ លោក ចូលរួមពីរដងជាសមាជិករដ្ឋាភិបាល : ទេសរដ្ឋមន្ត្រី ទទួលបន្ទុក ក្រសួងមហាផ្ទៃ និង ធម្មការ ក្នុងរដ្ឋាភិបាលលោក លន់ នល់, ទេសរដ្ឋមន្ត្រី ទទួលបន្ទុក ក្រសួងសាធារណៈការ និង ដឹកជញ្ជូន នៅក្នុងរដ្ឋាភិបាលទី១ របស់លោក ឡុង បូរេត។ លោក ជា អគ្គលេខាធិការ នៃគណបក្សសាធារណរដ្ឋ។ ហើយនៅឆ្នាំ ១៩៧៥ ពេលពួកខ្មែរក្រហម ចូលក្រុងភ្នំពេញ លោកត្រូវបានពួក នោះសម្លាប់លោក ជាមួយទ្រង់សិរិមតៈ។

បានស្នើដល់លោក អ៊ិន តាំ, នរៈនេះ ក៏ទទួលយល់ព្រម ដូចដែលបានជំរាបខាងលើរួចមកហើយ។

បន្ទាប់ពីចុះហត្ថលេខា នៃកិច្ចព្រមព្រៀងសន្តិភាពនៅឆ្នាំ ១៩៧៣ រវាង សហរដ្ឋអាមេរិក និង យួនខាងជើងមក ក្រុមនិមួយៗ ហាក់បីដូចជា នៅរក្សាគោលជំហរ របស់ខ្លួនរៀងៗខ្លួន តែយល់ស្របគ្នាលើចំណុចមួយថា ពួកយួនកុម្មុយនិស្ត នឹងប្រើគ្រប់មធ្យោបាយ ដើម្បី បំភាន់មតិអន្តរជាតិថា សង្គ្រាមនៅស្រុក ជាសង្គ្រាមស៊ីវិល ព្រោះទ័ពយៀកកុង បានដកចេញពីស្រុកខ្មែរ ស្របតាមកិច្ចព្រមព្រៀងសន្តិភាព។ ហេតុនេះឯង បានជាសាធារណរដ្ឋខ្មែរស្នើជាបន្ទាន់ដល់ពួកខ្មែរក្រហម នូវដំណោះស្រាយ រវាងខ្មែរនិងខ្មែរ តាមសន្តិវិធី។ ដោយអកុសល ពួកខ្មែរក្រហមបដិសេធ នូវសំណើរនេះ ដែលហុចឱកាសអោយទ័ពយួនកុម្មុយនិស្ត បន្តលាក់ខ្លួនបាននៅស្រុកខ្មែរ ដើម្បីបន្តធ្វើសង្គ្រាម នៅស្រុកខ្មែរ និង នៅយួនខាងត្បូង។ ត្រូវដឹងថាបន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាព សហរដ្ឋអាមេរិក បានកាត់ជំនួយយោធា ដល់សាធារណរដ្ឋខ្មែរ ស្របតាមសេចក្តីសម្រេច របស់សភាអាមេរិកាំង។ តែនៅលើសមរភូមិវិញ

ពួកយួនកុម្មុយនិស្ត គ្មានគោរពអ្វីបន្តិចបន្តួចឡើយ នូវកិច្ចព្រមព្រៀងសន្តិភាព ហើយថែមទាំងបញ្ជូន នូវរថក្រោះរាប់រយគ្រឿង ចូលមកក្នុងស្រុកខ្មែរ និង យួនខាងត្បូង នាំអោយភ្លើងសង្គ្រាម កាន់តែក្តៅឡើងៗ។ ទ័ពយួនក្រហម អាចប្រព្រឹត្តបែបនេះបាន ដោយសារតែ ទ័ពអាកាសអាមេរិកាំង លែងមានសិទ្ធិធ្វើអន្តរាគមន៍តាមការហាមឃាត់ដាច់ខាត ពីសភាអាមេរិកាំង នៅស្រុក ខ្មែរ, យួនខាងត្បូង និង យួនខាងជើង។ ចំណែក ពួកខ្មែរក្រហមវិញ កាន់តែទទួលជំនួយយោធា ពីចិន តាមរយៈយៀកកុង ផ្តល់ នូវអាវុធយុទ្ធភ័ណ្ឌទំនើបៗ សំរាប់ធ្វើការវាយលុកចូលទីក្រុងភ្នំពេញ និងកាត់ផ្លូវដឹកស្បៀងសំខាន់ៗ ដើម្បីបន្ទប់ នូវជីវិតរស់នៅ របស់ប្រជារាស្ត្រទីក្រុង។ ហេតុនេះឯង បានជាប្រជារាស្ត្រនេះ មាន សោមនស្ស និង ស្វាគមន៍ ដល់ពួកខ្មែរក្រហម ដើរចូលភ្នំពេញ នៅឆ្នាំ ១៩៧៥ ដោយមានជំនឿថា សង្គ្រាម រវាងខ្មែរនិងខ្មែរ វាច្បាស់ជាចប់ជាស្ថាពរ ហើយ រស្មីជីវិត នឹងរះឡើងវិញ សំរាប់ការរស់នៅ។ នេះហើយជាការស្រមើស្រមៃមួយ ដែលមានតម្លៃគ្រោះថ្នាក់ដល់ជីវិត ព្រោះ ជាមួយ ពួកកុម្មុយនិស្ត វា

មិនអនុញ្ញាត អោយមាន រស្មីជីវិតណា ដែលអាចនៅពីលើ ប្រយោជន៍បក្សបាននោះឡើយ។



លោក ខៀវ សំផន

# ករណីខ្មែរក្រហម

## ការរំឭកប្រវត្តិសាស្ត្រ

គណបក្សកុម្មុយនិស្តខ្មែរ ដែលយួន គេបង្កើតឡើងនៅថ្ងៃទី ២៥ មិថុនា ១៩៥១ តាមការសម្រេចចិត្ត នៃសមាជរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន គឺនៅពេលនោះ យួន គេបំបែកជាកលយុទ្ធថ្មី បក្សកុម្មុយនិស្តឥណ្ឌូចិន ជាបីមែក គឺ បក្សកុម្មុយនិស្ត យួន, ខ្មែរ និង លាវ នៃដើមឈើតែមួយ គឺថា បក្សកុម្មុយនិស្តយួន ជា ដើមឈើ។ ត្រូវដឹងថា នៅខែមិថុនា ឆ្នាំ ១៩៤១ បក្សកុម្មុយនិស្តឥណ្ឌូចិន តាមការសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គ (plénum) លើកទី៨ របស់ គណកម្មាធិការមជ្ឈឹម បង្កើត នៅស្រុកខ្មែរ ចលនាខ្មែរឥស្សរៈ[23] ដែលមានកម្មាភិបាលយួន ជាអ្នកដឹកនាំ ដើម្បី តស៊ូប្រដាប់អាវុធ ជាមួយបក្សកុម្មុយឥណ្ឌូចិន ប្រឆាំងនឹងអាណានិគមបារាំង។ បន្ទាប់ពី បញ្ចប់សង្គ្រាម

[23] យួនយកឈ្មោះ ចលនាខ្មែរឥស្សរៈ ដែលខ្មែរ ជាអ្នកបង្កើតមុនដំបូងនៅ ស្រុក សៀម មកប្រើ ដើម្បីបំភាន់ខ្មែរ។ សូមអាន សៀវភៅ ចរិតខ្មែរ និពន្ធដោយលោក ប៊ុណ្ណចន្ទ ម៉ុល។

លោកលើកទី២ និង បារាំង កាន់កាប់ឥណ្ឌូចិនឡើងវិញ តែ បារាំង ទទួលស្គាល់ស្រុកខ្មែរ ជាប្រទេសឯករាជ្យ នៅក្នុង សហភាពបារាំង នៅពេលនោះ គណបក្សប្រជាជនកម្ពុជា បានចេញធ្វើ សកម្មភាពនយោបាយចេញមុខចូលរួមបោះឆ្នោត បង្កើតសភាជម្មនុញ្ញ រហូតមកដល់សម័យសង្គមរាស្ត្រនិយម ទោះបីសកម្មភាពនោះ វាមានតិចតួចបំផុត យ៉ាងណាក្តី។ តែយួនកុម្មុយនិស្ត ពីឆ្នាំ ១៩៤៥ ដល់ ១៩៥៤ គេនៅរក្សា ក្រុមតស៊ូប្រដាប់អាវុធ នៅស្រុកខ្មែរ ដោយលាក់ខ្លួន ធ្វើជាខ្មែរឥស្សរៈ នៅក្នុង ចលនាខ្មែរឥស្សរៈ របស់យួន។ សន្និសិទ្ទ នៅទីក្រុង ស៊ីណែវ នៅឆ្នាំ ១៩៥៤ បង្ខំឲយួនកុម្មុយនិស្ត និង បារាំង ដកកងទ័ពចេញពីស្រុកខ្មែរ ក្រោមការត្រួតត្រា គណកម្មការ ត្រួតពិនិត្យអន្តរជាតិ របស់អង្គការសហប្រជាជាតិ។ ទព័យួនដកចេញពីស្រុកខ្មែរ ដោយនាំយកទៅជាមួយ ពួកខ្មែរស្ម័គ្រនឹងខ្លួន ចំនួនប្រមាណ ៤ពាន់នាក់ ទៅស្រុកយួនខាងជើង។ ពួកនេះឯង ដែលខ្មែរ ហៅថា « ខ្មែរយៀកមិញ »។ យួនដកទ័ពចេញពិត តែគេលាក់កម្មាភិបាល របស់គេមួយចំនួននៅស្រុកខ្មែរ ដើម្បីបន្តធ្វើសកម្មភាពលួចលាក់។ មេ

ដឹកនាំយួន នៅស្រុកខ្មែរនៅសម័យនោះ មានឈ្មោះថា Pham Van Ba។ ជននេះឯង ដែលជាគ្រូនយោបាយ របស់ ប៉ុល ពត នៅជុំរុំពួកយៀកម៉ិញ នៅភ្លសាន នៃស្រុកខ្មែរ។ នៅសម័យនោះ ពួកយៀកម៉ិញ គេបែងចែកស្រុកខ្មែរ ជាបីដំបន់ : នៅដំបន់ ភ្លសាន, ពាយ័ត្រ និង បុ៉ា និង មូលដ្ឋានយោធា នៅក្នុងខេត្ត ស្ទឹងត្រែង។ ក្រោយពី សន្និសិទ្ទ នៅទីក្រុង ស៊ីណែវ និង ការអំពាវនាវ របស់សម្តេច សីហនុ នៅថ្ងៃទី ៧ កុម្ភ: ឆ្នាំ ១៩៥៤ សូមឲខ្មែរចូលរួម បូជនីយកិច្ច ទាមទារឯករាជ្យ ប៉ុល ពត បានត្រូវ Pham Van Ba បញ្ជាឲវិលត្រឡប់ មកទីក្រុងភ្នំពេញវិញ នៅថ្ងៃទី ២០ កក្តដា ឆ្នាំ ១៩៥៥ ដើម្បី ធ្វើបេសកកម្មវិទ្ទស្សនា ជាពិសេស ចូលធ្វើការ នៅក្នុង គណបក្សប្រជាធិបតេយ្យ។

នៅឆ្នាំ ១៩៦០ យួនកុម្មុយនិស្ត សម្រេចចិត្ត វាយប្រហារ យួនខាងត្បូង តាមកម្លាំងទ័ព ដោយបំពាន នូវកិច្ចព្រមព្រៀងសន្តិភាព នៃសន្និសិទ្ទ នៅទីក្រុង ស៊ីណែវ។ នៅពេលនោះ ពួកយៀកម៉ិញ ត្រូវការជំនួយ ពីពួកកុម្មុយនិស្តខ្មែរ នៅក្នុងស្រុក។ យួន ឈ្មោះ Nguyen Than Son ជាអ្នកទទួលបេសកកម្មភាព នៅស្រុកខ្មែរ រៀបចំឡើងវិញ នូវ

រចនាសម្ព័ន្ធ នៃកុម្មុយនិស្ត នៅស្រុកខ្មែរ ស្មើដល់ពួកខ្មែរកុម្មុយនិស្ត ឲចូលធ្វើសហការ ក្នុងបេសកកម្មនេះ ដូច្នេះ បានជាមាន ការប្រជុំសម្ងាត់មួយ នៅស្ថានីយអយស្ម័យយាន នៅទីក្រុងភ្នំពេញ រវាងខ្មែរកុម្មុយនិស្ត ២១នាក់ ជាមួយ Nguyen Than Son។

ផែនការ របស់ Nguyen Than Son គឺ :

- ម្យ៉ាង កាន់ផ្ដាច់ គមនាគមន៍ រវាង Saigon និង លាវ ម្យ៉ាងទៀត រវាង Saigon និង ភ្នំពេញ ហើយនិង ភ្នំពេញ និង បាត់ដំបង;
- បង្កើត មូលដ្ឋានយោធា មាំទាំ នៅក្នុងដំបន់ នីរតី និង ព្លៃសាន ដើម្បីកាន់កាប់ ខេត្តមហទ្ធន មាន ខេត្ត បាត់ដំបង, ពោសាត់, កំពុងឆ្នាំង និង កំពត ហើយ និង បើកផ្លូវគមនាគមន៍ ជាមួយប្រទេសសៀម និង ប្រទេសដទៃទៀតនៅ អាស៊ី-អគ្នេយ៍។ ដើម្បីធ្វើឲបាន សម្រេច នូវផែនការនេះ Nguyen Than Son ត្រូវ ចាំបាច់បង្កើត ផ្នែកភូមិសាស្ត្រពីរ គឺមាន : ផ្នែក ខាងកើត នៃទន្លេមេកុង្គ ឲឈ្មោះថា « គមនាគមន៍ និង សង្គ្រាមសេដ្ឋកិច្ច », ចំណែក ផ្នែក ខាងលិច នៃ

> ទន្លេមេគង្គ ឲឈ្មោះថា « ផ្នែកយោធា »។ នៅក្នុងយុទ្ធសាស្ត្រនេះ ពួកយៀកមីញ គេទុក ដំបន់ទន្លេសាបជា មូលដ្ឋានចម្បង។ តាមទ្រឹស្តី របស់ Nguyen Than Son មូលដ្ឋាន ដ៏ប្រសើរ មិនចាំបាច់តែ លាក់ខ្លួននៅក្នុងព្រៃស្មសាន ឬ ក្នុងដំបន់ព្រៃភ្នំដាច់ស្រយ៉ាល នោះទេ តែគេអាចបង្កើត នៅកន្លែងទីវាលមើលឃើញដែលមានសន្ទភាពប្រជាជន រស់នៅយ៉ាងច្រើន[24]។

តែនៅក្នុងយុទ្ធសាស្ត្រនេះ យួនកុម្មុយនិស្ត ត្រូវការសម្តេចសីហនុ ជាចាំបាច់ ព្រោះពួកគេ ត្រូវការដែនដីខ្មែរជៀសមិនរួច យកធ្វើជាមូលដ្ឋានយោធាខាងក្រោយ។ តែបំណងនេះ វាមិនជួបឧបសគ្គពិបាកនោះឡើយ ព្រោះថា ចាប់ពី

[24] ដើម្បីពង្រឹងពង្រិចមូលដ្ឋានសេដ្ឋកិច្ច Nguyen Than Son នាំចូលជនជាតិយួនខាងត្បូង ដែលមានចិត្តស្រឡាញ់កុម្មុយនិស្ត មកក្នុងស្រុកខ្មែរ ដើម្បីប្រកបរបររកស៊ីតាមច្រាំងទន្លេប៉ាសាក់ និងមេគុង ហើយនៅក្នុងអំឡុងឆ្នាំ ១៩៦៥-១៩៦៧ ពួកយួនទាំងនោះបន្តដំណើរតាមទូក រហូតមកដល់ខេត្តតាកែវ និង ពោសាត់ រួចមកតាំងជម្រោកអណ្តែតក្នុងបឹងទន្លេសាបតែម្តង។ សម្តេច សីហនុ ព្រះអង្គបិទភ្នែក នៅចំពោះមុខ ការរុកចូលនេះ ព្រោះវាជានយោបាយ របស់ទ្រង់។

សម្តេច សីហនុ មានទំនាក់ទំនង ជាមួយ ចិនកុម្មុយនិស្តមក[25] ព្រះអង្គ បានត្រៀមខ្លួនរួចរាល់ហើយ ដើម្បីចូលរួមជាមួយពួកកុម្មុយនិស្ត។ នៅក្នុងឱឡាន ផ្កាកុលាបក្រហមចិន មានក្លិនពិដោរ នាំឲព្រះអង្គ ឥតមើលឃើញទងផ្កាកុលាប ដែលមានពាសពេញដោយបន្លាស្រួចដូចម្ជុលនោះឡើយ។ ការបែរទៅរកលោកកុម្មុយនិស្តនេះ នាំទៅរកការចាត់ការមួយចំនួន របស់ព្រះអង្គ គឺ ការផ្តាច់ទំនាក់ទំនងតាមផ្លូវទូត ជាមួយ យួនខាងត្បូង នៅថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៦២, នៅថ្ងៃទី១៩ វិច្ឆិកា ឆ្នាំ ១៩៦៣ ការបដិសេធ ជំនួយអាមេរិកាំង និង បាតុករ ឡោមព័ទ្ធ វាយចូល ស្ថានទូត សហរដ្ឋអាមេរិក និង អង់គ្លេស, នៅថ្ងៃទី ១១ មីនា ឆ្នាំ ១៩៦៤ ប្រទេសកម្ពុជា ដាក់ពាក្យបណ្តឹង ទៅក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ ស្តីពី ការឈ្លានពាន នៃកងទ័ពអាមេរិកាំង និង យួនខាងត្បូង ចូលមកក្នុងដែនដីកម្ពុជា, នៅខែមិនា ឆ្នាំ ១៩៦៥ មាន

---

[25] ខ្មែរ និង ចិនប្រជាមានិត ចុះហត្ថលេខារួម នៅថ្ងៃទី១៨ ធ្នូ ឆ្នាំ ១៩៦០ ស្តីពី មិត្តភាព មិនឈ្លានពានគ្នាទៅវិញទៅមក។

ការជួបជជែកគ្នា រវាង ខ្មែរ និងយួនខាងជើងនៅទីក្រុងប៉េកាំង, នៅថ្ងៃទី៣ មេសា ឆ្នាំ ១៩៦៥ កម្ពុជា ប្រកាសផ្តាច់ការទាក់ទងតាមផ្លូវទូត ជាមួយសហរដ្ឋអាមេរិក, នៅថ្ងៃទី១១ មេសា ឆ្នាំ ១៩៦៦ កម្ពុជា និង យួនខាងជើង ចាប់ផ្តើមមានទំនាក់ទំនងតាមផ្លូវទូត។ ទំនាក់ទំនងនេះ គឺជាការបង្ហាញ នូវសាមគ្គីភាពបន្ថែម ខ្មែរ និង យួនកុម្មុយនិស្ត ឆ្លើយតបនឹង ការបញ្ជូនកងទ័ពអាមេរិកាំង មកតាំងទីនៅយួនខាងត្បូង នៅថ្ងៃទី៨ មិនា ឆ្នាំ ១៩៦៦។

នយោបាយ របស់សម្តេច សីហនុ បែរទៅរក យួន និង ចិនកុម្មុយនិស្តនេះឯង ដែលនាំ បង្កើតព្រឹត្តិការណ៍ ថ្ងៃទី១៨ មីនា ឆ្នាំ ១៩៧០ គឺសភាជាតិ បោះឆ្នោតទម្លាក់សម្តេច សីហនុ ពីតំណែង ប្រមុខរដ្ឋ។ ហើយដោយក្តៅក្រហាយ នូវទង្វើនេះ ព្រះអង្គបានផ្សាយសារពីទីក្រុងប៉េកាំង នៅថ្ងៃទី២៣ មីនា ឆ្នាំ ១៩៧០ អំពាវនាវហៅកងទ័ពយួនខាងជើង និងយៀកកុង បានមកតាំងទី ពាសពេញលើទឹកដីខ្មែរស្រាប់តាមការសមគំនិត របស់ទ្រង់នោះ ឲបើកការវាយប្រហារស្រុកខ្មែរ ដើម្បីជួយខ្លួន ឲវិលត្រឡប់មកកាន់អំណាចវិញ, មូលហេតុនេះឯង ដែលនាំឲស្រុកខ្មែរកើតសង្គ្រាម។

នៅថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥, កងទ័ពជាតិខ្មែរ ព្រមដាក់អាវុធ ប្រគល់អោយ កងទ័ពបដិវត្តន៏ខ្មែរក្រហម ក្នុងនាមសន្តិភាព និង ការបង្រួបបង្រួមជាតិ រវាងខ្មែរនិងខ្មែរ។ ដំណឹងនេះ នាំអោយប្រជាពលរដ្ឋខ្មែរ ជាពិសេសអ្នកនៅទីក្រុងភ្នំពេញ ទទួល អបអរសាទរ ដល់យោធាខ្មែរក្រហមដើរចូលទីក្រុង ដោយមានជំនឿជាក់ច្បាស់ថា សង្គ្រាមអស់រយៈពេល៥ឆ្នាំ កន្លងមកនេះ ដែលនាំអោយ ប្រជាជាតិទទួល នូវមហាចង្រៃ វាច្បាស់ជាចប់ ជាពុំខាន។ តែសេចក្តីរីករាយនេះ វាប្រែក្លាយយ៉ាងរហ័ស ទៅជាសេចក្តីទុក្ខព្រោះពួកខ្មែរក្រហមបង្ខំអោយចាកចេញពីផ្ទះសំបែង និងទីក្រុង ដោយបំភ័យថា ខ្លាចអាមេរិកាំងទំលាក់គ្រាប់បែកមកលើទីក្រុង។ នៅក្នុងសៀវភៅ និពន្ធដោយលោក ខៀវសំផន បោះផ្សាយជាភាសាបារាំង នៅឆ្នាំ ២០០៤[26]។

[26] Histoire récente du Cambodge et mes prises de position – Edition Harmattan. ប្រវត្តិសាស្រ្តទើបកើតថ្មីនៅកម្ពុជា និង ការប្រកាន់គោលជំហរ របស់ខ្ញុំ។

លោក ខៀវ សំផន បានលើកយកមូលហេតុទី១ ថា ដែល អង្គការលើ តម្រូវចាត់វិធានការ ជម្លៀស ប្រជារាស្ត្រ រស់នៅទីក្រុងភ្នំពេញ ព្រោះអង្គការ គ្មានមធ្យោបាយអាចផ្តល់ស្បៀងដល់ប្រជារាស្ត្រ បីលាននាក់ រស់នៅទីនោះ ដ្បិត ផ្លូវ ថ្នល់ និង ស្ពាន សំរាប់ដឹកជញ្ជូនស្បៀង បានបាក់បែក គ្មានសល់ នៅពេលសង្គ្រាម។ មូលហេតុទី២ គឺ បញ្ហា សន្តិសុខ និង ការពារ ពោលថា ក្នុងពេលនោះ ឆន្ទៈ នៃអនុត្តរភាព (hégémonie) របស់យៀកណាម នឹងអាចក្លាយជាការពិត និង កាន់តែសម្បើមឡើង មកលើកម្ពុជា, ទីក្រុងភ្នំពេញ ដែលជាជម្រង នូវពួកបនចោរគ្រប់ប្រភេទ នឹងអាចក្លាយទៅជា ទីកន្លែង អនុគ្រោះអោយពួកនោះ ធ្វើការបំរើពួក CIA, បន លន់ នល់ និង ខ្មែរសេរី។

យើងឃើញថា មូលហេតុ ដែលលោក ខៀវ សំផន លើកមកនិយាយនេះ វាគ្មានសមហេតុសមផលសោះ តែនរ:នេះ ដើម្បី កុំអោយខ្លួនជាប់ទាក់ទង និង ទទួលការខុសត្រូវរួមក្នុងវិធានការនោះ បានសរសេរបន្ថែមថា ខ្លួនលោក មិនយល់ស្របនោះទេ ព្រោះអង្គការលើ អាចមានដំណោះស្រាយផ្សេងទៀត គឺលើកយកគំនិតស្នេហាជាតិ ធ្វើជាកម្លាំង

រួបរួមជាតិ ដែលវានឹងអាច ដោះស្រាយ នូវបញ្ហាទាំងពីរ នេះបាន។

លោក ខៀវ សំផន សរសេរបន្តទៀតថា នៅពេលសន្ទនាជាឯកជន ជាមួយលោក ប៉ុល ពត, នរៈនេះ បានពន្យល់លោកថា វិធានការនេះ មានចារនៅក្នុងផែនការ នៃនយោបាយ នៃសមូហភាវកម្ម ដើម្បី បង្កើតផលស្រូវ ដែលជាអាវុធទី១ សំរាប់ប្រទល់មុខនឹង អនុភាពយោធា នៃយៀកណាម ហើយនឹងនាំគេអោយគោរព នូវអធិបតេយ្យភាពជាតិខ្មែរ នៅពេលដែលទ័ពគេ បន្តតាំងទីនៅក្នុងទឹកដីខ្មែរ។

លោក ខៀវ សំផន បញ្ជាក់បន្ថែមថា គោលដៅសំខាន់របស់លោក ប៉ុល ពត បន្ទាប់ពីជ័យជំនះ គឺរៀបចំជាបន្ទាន់ស្រុកខ្មែរ អោយចំរើនលូតលាស់មុនយៀកណាម តាមផែនការ អភិវឌ្ឍន៏ជនបទ។ របបថ្មី នឹងត្រូវមានមធ្យោបាយ ធានា នូវការរស់នៅដ៏ប្រសើរ នៃប្រជាជន, នឹងធ្វើអោយមានឡើងវិញ នូវឯកភាពជាតិ នៅក្នុងមូលដ្ឋានថ្មី ប្រកបដោយយុត្តៈប្រសើរ។ គឺរហូតដល់ពេលនោះឯង និង នៅពេលនោះឯង ដែលយៀកណាម គេនឹង

ទទួលស្គាល់ ស្រុកខ្មែរជាប្រជាជាតិមួយ និង ធ្វើទំនាក់ទំនង ស្មើគ្នា រវាង យៀកណាម ជាមួយ ប្រទេសកម្ពុជា ហើយឈប់ចូលជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុង របស់កម្ពុជា។ ចំពោះលោក ខៀវ សំផន ផែនការនេះ គឺការបន្តអនុវត្ត សេដ្ឋកិច្ចសង្គ្រាម នៅក្នុងពេលសន្តិភាព ដែលលោកយល់ឃើញថា ជាការយល់ច្រឡំមួយ ព្រោះ ប្រជាជនខ្មែរ នៅជនបទ រងកម្មនឹងសង្គ្រាម អស់រយះពេល៥ឆ្នាំ ត្រូវការការសំរាកកាយ និង ចិត្ត មួយរយះពេល ហើយប្រជាជនទីក្រុង ក៏ត្រូវការ រយះពេលខ្លីមួយដែរ ដើម្បីសម្របខ្លួន ទៅតាមជីវភាពខ្លួនថ្មី។

យើងឃើញថា គំនិត របស់ ប៉ុល ពត វាមិនស្របគ្នានឹងសកម្មភាព។ ដូច្នេះ វាមិនអាចបង្កើតបាន លទ្ធផល បាននោះដែរ។ ដូច្នេះដែរ បញ្ហា នៃអនុត្តរភាពយៀកណាម វាបង្អង់នៅដដែល ព្រោះ កម្ពុជាថ្មី មិនអាចបង្កើតបានឡើងវិញ នៃកម្លាំងជាតិខ្មែរ ដែលវាខុសគ្នាពីកម្លាំងបដិវត្តន៍។ នៅក្នុងចំណុចនេះឯង ដែលលោក ប៉ុល ពត យល់ច្រឡំទាំងស្រុង ហើយដឹកនាំ កម្ពុជា ដើរឆ្ពោះទៅរកចង្កូមយៀកណាម ទៅវិញ ដែលវាខុសពីគំនិត របស់គាត់។

ពិតណាស់ហើយថា យៀកណាម គេ បង្កប់ រនុក របស់គេជាច្រើន នៅក្នុងក្រុមខ្មែរក្រហមគ្រប់ថ្នាក់ ជាពិសេសនៅក្នុងជួរកងទ័ព ព្រោះកងទ័ព គ្មានឯកភាពទេ ហើយនៅពេលសង្គ្រាម (១៩៧០-១៩៧៥) កងទ័ពនេះឯង ដែល មេដំបន់និមួយៗ ត្រូវការជំនួយ ពីទ័ពយួនកុម្មុយនិស្ត នៅក្នុងស្រុកខ្មែរ។

គួរលើកយកសំណេរលោក ខៀវ សំផន មកបង្ហាញ អំពីទំនាស់ព្រំដែន រវាង កម្ពុជាប្រជាធិបតេយ្យ និង យៀកណាម បន្ទាប់ពីសង្គ្រាម។

នៅឆ្នាំ ១៩៧៦ មានការចរចាមួយចំនួន រវាងប្រទេសទាំងពី ស្ដីអំពីបញ្ហាព្រំដែន តែការចរចានោះ គ្មានលទ្ធផលអ្វីនោះឡើយ។ ត្រូវដឹងដែរថា នៅឆ្នាំ ១៩៧៥ ពួកអ្នកដឹកនាំខ្មែរក្រហមមួយចំនួនធំ ដឹកនាំដោយលោក ប៉ុល ពត បានទៅទីក្រុងហាណូយ ដើម្បីស្វែងរក សន្ធិសញ្ញា មិត្តភាព និង សហការ ក្នុងរយៈពេលយូរ រវាង កម្ពុជា-យៀកណាម ដើម្បី ធ្វើជាមូលដ្ឋាន នៃដំណោះស្រាយ តាមសន្តិវិធី និង មិត្តភាព នៃជម្លោះព្រំដែន ផ្អែកទៅលើការប្រកាសរួម និង ជាឧឡារិក នៃប្រទេសទាំងពីរ នៅឆ្នាំ ១៩៦៧។ តែនៅ

ពេលនោះ យៀកណាម ជៀសវាង លើកយកបញ្ហានេះមកនិយាយ ហើយ ស្នើជួបជាថ្មី នៅខែមិថុនា ឆ្នាំដដែរ។ តែ កម្ពុជា នៅតែចចេស ស្នើដាក់ក្នុងរបៀបវរៈ នូវបញ្ហាព្រំដែន ដែលនាំអោយយៀកណាម លុបចោល គំរោងជំនួប។ ត្រូវដឹងដែរថា អ្វីជាចំណុចផ្ទុយគ្នា រវាង កម្ពុជា-យៀកណាម ក្នុងជំនួប នៅឆ្នាំ ១៩៧៦, នៅពេលប្រជុំនោះ លោក ផាន់ ហៀង, អនុរដ្ឋមន្ត្រីក្រសួងកិច្ចការបរទេសយៀកណាម មិនត្រឹមតែ បញ្ជាក់ដល់កម្ពុជាថា ទឹកដីតាមព្រំដែន ដែលមានទ័ពយួនកាន់កាប់ ជាដែនដីយួន ហើយយៀកណាម បដិសេធទទួលស្គាល់ នូវខ្សែគូស Brévié ជាខ្សែព្រំដែនសមុទ្រ រវាង កម្ពុជា-យៀកណាម។ ចំណែក កម្ពុជា ពេលនោះ រៀបបំរុងនឹងធ្វើសម្បទាន លើដែនដីមួយចំនួន ដែលខ្សែសីមាពន្ធន៍ គ្មានភាពពិតប្រាកដ។ តែយៀកណាម ស្នើដោយចចេស ពិនិត្យឡើងវិញ នូវព្រំដែនសមុទ្រ ក្នុងផ្នែកដែលនាវាអាចបើកបាន នៅមុខ ក្រុងកំពត និង ក្រុងកែប និង មួយផ្នែកធំ ក្នុងផ្ទៃទឹក មានជម្រៅជ្រៅ នៅមុខកំពង់ផែកំពង់សោម ដែល កម្ពុជា មិនអាចទទួលយក

សំណើរនេះបាន[27]។ ក្រោយពីបរាជ័យ នៃជំនួបនោះ កម្ពុជា និង យៀកណាម នៅមានទំនាក់ទំនង ក្នុងកំរិតមិត្តភាព ធម្មតា តែវាគ្រាន់តែ សំរាប់ពន្យា នូវព្រឹត្តិការណ៍អាក្រក់បំផុត ដែលវានឹងកើតឡើង។ ការទាមទារ របស់យៀកណាមទាំងឡាយ វាបង្ហាញ នូវគំនិត នៃអនុត្តរភាពយួន មកលើកម្ពុជា ជាប្រវត្តិសាស្ត្រ ដែលនាំអោយកម្ពុជា មិនព្រមទទួល នូវការអញ្ជើញ របស់យៀកណាម ចូលរួមប្រជុំកំពូលឥណ្ឌូចិន ដែលយៀកណាម គ្រងធ្វើនៅថ្ងៃទី ១៥ កុម្ភៈ ឆ្នាំ ១៩៧៧ នៅស្រុកយួន។ ដូច្នេះ ភាពតានតឹង វាកាន់តែវាតធំឡើងៗ បណ្តាលអោយមាន ការវាយប្រហារ នៃកង

---

[27] ក្នុងចំណុចនេះ ក្នុងគំនិតថោកទាបបំផុត របស់លោក ខៀវ សំផន គាត់ឆ្លៀតសរសេរ ដាក់កំហុស លើលោក លន់ នល់ ថានៅសម័យសីហនុ កាន់អំណាច លោក លន់ នល់ នេះឯង ដែលអនុញ្ញាតអោយទ័ពតស៊ូយួន ឬ យៀកកុង មករស់នៅក្នុងតំបន់នោះ។ សំណេរនេះ បង្ហាញអោយឃើញកាន់តែច្បាស់ឡើង នូវ ភាពកំសាក និង ថោកទាប របស់គាត់។ ត្រូវដឹកថា យៀកកុង មកទាំងមូលដ្ឋាននៅស្រុកខ្មែរ គឺ សម្តេចសីហនុ ជាអ្នកអនុញ្ញាតតែម្នាក់ឯង ហើយនៅពេលនោះ ការអនុញ្ញាតនោះ ខ្មែរទុកជានយោបាយជាន់ខ្ពស់ របស់សម្តេចឪ ដែលគ្មាននរណាម្នាក់ហ៊ានប្រឆាំងបាននោះឡើយ។

កម្លាំងខ្មែរក្រហម ចូលទៅក្នុងទឹកដីយួន ក្នុងភូមិ Tinh-Bien ក្នុងខេត្ត An Giang[28] (ឈ្មោះខ្មែរ គឺ ពាមបារាជ-មាត់ជ្រូក, ខេត្តនេះ ស្ថិតនៅក្នុងទឹកដីកម្ពុជាក្រោម)។ ប្រតិកម្មយួន គឺ ការទម្លាក់គ្រាប់បែប ដោយយន្តហោះ A. 37[29] និង បាញ់កាំភ្លើងធំ ហើយវាយលុកចូលមកក្នុងទឹកដីខ្មែរ គាំទ្រដោយរថក្រោះ រហូតមកដល់មាត់ទ្វារទីក្រុងនៃខេត្តស្វាយរៀង ដើម្បី តបនឹងការវាយប្រហារ របស់កងទ័ពខ្មែរក្រហម។ មកដល់ខែ កញ្ញា មានការលុកលុយថ្មីម្តងទៀត ពីសំណាក់ទាហ៊ានខ្មែរក្រហម ចូលទៅក្នុងភូមិយួនមួយចំនួន នៅក្នុងខេត្ត Tay-Ninh (រោងដំរី) និង Ha-Tieng (ពាម)។ ពេលនោះ ទាហ៊ានខ្មែរក្រហម បានសម្លាប់យ៉ាងសាហាវប្រជាជានយួនស្លូតត្រង់ជាច្រើន។ ចំពោះខ្មែរ

---

[28] ខេត្តនេះ ជាឈ្មោះថ្មី គឺ រួមបញ្ចូលគ្នាពីខេត្ត គឺ Long Xuyen, Chaudoc។

[29] យន្តហោះនេះ ជាយន្តហោះអាមេរិកាំង ទុកចោលនៅស្រុកយួន នៅពេលកងទ័ពអាកាសអាមេរិកាំងដកចេញពីស្រុកយួន។

ក្រហម ការលុកលុយយោធានេះ គឺជាការតបនឹងរឿងហេតុមួយចំនួន ដែលយួនជាអ្នកបង្កើតមុន។

នៅក្នុងសៀវភៅ របស់លោក ខៀវ សំផន គាត់បានបន្ទោស នូវល្បាក់ទឹកយោធាទាំងឡាយនោះ តែលោក ក៏សួរជាសំនួរដែរថា : ពិតណាស់ ដោយគ្មាន កសិណឯករាជ្យ, ដូច្នេះ ទង្វើ ដែលបណ្តាលឲកើតមានរឿងហេតុ នៅតាមព្រំដែន វាស្ថិននៅឡើយ លើការស្វែងរក នូវការពិត និងនៅជាប្រស្នា សំរាប់ពួកអ្នកសង្កេតការណ៍ : តើហេតុអ្វីបានជា ប្រទេសតូចមួយ ហើយ ខ្សោយ ហ៊ានផ្តើន និង នាំខ្លួន អោយរាតត្បាត ដល់ប្រទេសជិតខាងខ្លួន ដែលមានឬទ្ធានុភាព លើសខ្លួន រហូតគ្មានអ្វី នឹងអាចយកមកប្រៀបផ្ទៀបបាន ?

យើងអាចសួរជាសំនួរពីរទៅលោក ខៀវ សំផន វិញថា :

តើហេតុអ្វី បានជាក្រុមខ្មែរក្រហម ជួយយួនកុម្មុយនិស្តអោយវាយប្រហារ កងទ័ពជាតិខ្មែរ នៅពេលសង្គ្រាម ក្នុងអំឡុងឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧៥ ?

តើហេតុអ្វី បានជាក្រុមខ្មែរក្រហម បដិសេធ ចូលមកចរចា រកដំណោះស្រាយ នៃជម្លោះ រវាង ខ្មែរ និង ខ្មែរ ដែលស្នើដោយសាធារណរដ្ឋខ្មែរ នៅក្នុងក្របខណ្ឌ នៃកិច្ចព្រមព្រៀងសន្តិភាព នៅឆ្នាំ ១៩៧៣ ?

ពិតណាស់ហើយថា យៀកណាម មានមហិច្ឆិតា ជាប្រវត្តិសាស្ត្រ ឈ្លានពានទឹកដីខ្មែរ ហើយខ្មែរ គ្រប់ជំនាន់តជាលំដាប់ តែងតែចងចាំ កត់ទុកនៅក្នុងសតិរួមថា មហិច្ឆិតាយួននេះ វាមិនរលត់ជាដាច់ខាត ដូនជារងើក លាក់ខ្លួន ដូចជាកំញម[30] ហើយនៅពេលណាមានខ្យល់បក់ត្រូវ ជាឱកាសអោយវាឆេះឆ្លោឡើង។ ពួកខ្មែរក្រហមហ្នឹងហើយ ជាខ្យល់ជាឱកាស តាំងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ អោយរងើកយួន ឆេះបានយ៉ាងងាយស្រួលនៅលើទឹកដីខ្មែរ ដែលនាំបង្កើតមហាជោគជ័យយួន នៅថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩។ ការណ៍នេះ បង្ហាញ នូវអសមត្ថភាព នៃក្រុមខ្មែរក្រហមក្នុងការ ការពារប្រជាជាតិខ្មែរ គ្រប់ទ្រង់ទ្រាយ គឺ បញ្ញា,

[30] ផែះ រលុត។

បដិវត្តន៍, រដ្ឋ និង ជា អ្នកដឹកនាំ។ ដូច្នេះ ក្រុមខ្មែរក្រហម ជាសប្បិករ នៃបរាជ័យ នៃប្រជាជាតិខ្មែរ នៅចំពោះមុខ មហិច្ឆិតាយួន។ គំនិតបដិវត្តន៍ របស់ក្រុមខ្មែរក្រហម វាកំសោយកម្លាំងជាតិ រួចធ្លាក់ចូលក្នុងអន្ទាក់បច្ចាមិត្ត នាំអោយខ្លួន ពិការភ្នែក ពិការស្មារតី យកប្រជាពលរដ្ឋខ្លួនឯង ជាសត្រូវ ក៏ចុះខ្សោយ ដោយឯងឯង នាំគ្នារត់រប៉ាត់រប៉ាយ នៅចំពោះមុខ ការវាយប្រហារ ពីសំណាក់កងទ័ពយួន។

ត្រូវដឹងថា តាំងពីដើមទីមក វាមានការបែកបាក់គ្នា នៅក្នុងជួរអង្គការលើ របស់ពួកខ្មែរក្រហម។ ក្រុមពីរ មួយនិយមយួន និងមួយទៀត និយមចិន ប្រឆាំងគ្នាជួនកាលចេញមុខ ជួនកាលសម្ងាត់ រហូតដល់ឆ្នាំ ១៩៧៧ ក្រុម និយមចិន ដែលដឹកនាំដោយ ប៉ុល ពត ជាអ្នកមានជ័យជំនះ។ ក្រុមនេះ បានធ្វើ រេចនកម្ម ដ៏ពិសាលមួយ (une vaste purge) ពេញផ្ទៃនគរ ដែលនាំឲកម្មាភិបាលមួយចំនួន រត់គេចខ្លួន មកពួនខ្លួន នៅតាមព្រំដែនខ្មែរ-សៀម និង ព្រំដែន ខ្មែរ-យួន។ បើយោងតាមការចុះផ្សាយ នៃកាសែត Herald Tribune នៅថ្ងៃទី ៩ ធ្នូ ឆ្នាំ

១៩៧៧ មានកើតហេតុមួយចំនួន នៅថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៧ នៅតាមបណ្ដាខេត្ត ក្នុងដំបន់ ពាយ័ត្យ។ ក្នុងពេលនោះ មានការរួមគំនិតក្បត់មួយ ពីសំណាក់ កម្មាភិបាល នៃខេត្ត បាត់ដំបង ឧត្ដមានជ័យ សៀមរាប និង កំពុងជំគ្រោងធ្វើរដ្ឋប្រហារ ទំលាក់ ប៉ុល ពត។ ពិត ឬ មិនពិត តែ ប៉ុល ពត យកការនេះ ជាលេស ដើម្បី ធ្វើរេចនកម្មប្រិតប្រៀងមួយ ក្នុងជួរអ្នកដឹកនាំបក្សថ្នាក់ដំបន់ និង ថ្នាក់អង្គការលើ។ នៅដំបន់ខ្លះ មានការផ្លាស់ប្ដូរពួកកម្មាភិបាល បីដង ក្នុងរយៈពេលតែ ៩ខែ ប៉ុណ្ណោះ ជាពិសេស នៅដំបន់ មស្ទឹម នៃទន្លេមេគង្គ។ ការចោសសំអាត ជនក្បត់បក្សនោះ គឺសំដៅលើ ពួកនិយមយួន និង សីហនុនិយម។



សម្ដេច សីហនុ ជាមួយ នឹង សម្ដេច សឺន សាន

## ករណីចលនាតស៊ូខ្មែរ នៅតាមព្រំដែន ខ្មែរ-ថៃ

កងទ័ពយួន ចាប់ផ្ដើមវាយចូលស្រុកខ្មែរ ជាប្រតិបត្តិការសឹកធំ ក្នុងខែធ្នូ ឆ្នាំ ១៩៧៨។ នៅថ្ងៃទី២ មករា ឆ្នាំ ១៩៧៩, សម្ដេច សីហនុ ត្រូវបានពួកខ្មែរក្រហម ជម្លៀសចេញពីទីក្រុងភ្នំពេញ នាំទៅក្រុងស៊ីសូផុន។ ថ្ងៃទី៦ មករា ក្រុមអ្នកដឹកនាំអង្គការលើ បាននាំគ្នាចាកចេញ ពីទីក្រុងភ្នំពេញជាបន្ទាន់។ ថ្ងៃទី៧ មករា ភ្នំពេញរលំ ហើយ កងទ័ពយួនចូលកាន់កាប់ រួចបន្ត វាយប្រហារកងទ័ពខ្មែរក្រហម រហូតដល់ព្រំដែនថៃ។ នៅ ពាមជីលួស ក្បែរភូមិ សំឡូត ស្ថិតនៅជើងភ្នំក្រវាញ ប៉ុល ពត បានកោះប្រជុំ អ្នកដឹងនាំសំខាន់មួយចំនួន ដែលរត់គេចរួចពីសំណាញ់យួន។ ពេលប្រជុំនោះ ប៉ុល ពត បានសុំលាលែងពីតំណែង, មូលហេតុលើកឡើង គឺការទទួលខុសត្រូវ របស់គាត់នៅចំពោះមុខបរាជ័យជាក់ស្ដែង របស់កងទ័ពខ្មែរក្រហម។ តែនៅពេលនោះ ពួកអ្នកចូលប្រជុំ បានបដិសេធ នូវការសុំលាលែងនេះ ដោយលើកមូលហេតុថា ពេលនេះ មិនមែនជាពេលដែល ត្រូវរកមុខអ្នកណាមួយ ជាអ្នកទទួលខុសត្រូវនោះឡើយ ហើយក៏គ្មាននរណាម្នាក់ អាចជំនួស ប៉ុល ពត បាន

នោះដែរ ដូច្នេះ ជាពេល ដែលត្រូវតែរិតសាមគ្គីគ្នាទៅវិញទេ ដើម្បី ស្វែងរកជាថ្មី នូវខ្សែនាយក នៃការតស៊ូនយោបាយ ប្រឆាំងនឹង ការកាប់កាប់យួននៅកម្ពុជា។

ក្រោយពីការវាយលុកយួនភ្លាមនេះមក, អង្គការសហប្រជាជាតិ នៅតែទទួលស្គាល់ កម្ពុជាប្រជាធិបតេយ្យ ជាតំណាងប្រជាពលរដ្ឋខ្មែរដដែល ហើយនៅថ្ងៃទី៩ មករា ឆ្នាំ ១៩៧៩, សម្តេចសីហនុ បានយាងទៅទីស្តី នៃទីប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ ក្នុងនាម ជាអ្នកតំណាងជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ដើម្បី ប្តឹងអំពី ការឈ្លានពានដល់បូរណភាពទឹកដី និង អធិបតេយ្យភាពខ្មែរ ពីសំណាក់កងទ័ពយួន។ បន្ទាប់មកព្រះអង្គ បានយាងទៅគង់នៅទីក្រុងប៉េកាំងវិញ។ នៅថ្ងៃទី៩ តុលា ឆ្នាំ ១៩៧៩ សម្តេច សឺនសាន បានប្រកាសនៅក្នុងទឹកដីខ្មែរ បង្កើត រណសេរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ។ នៅថ្ងៃទី៩ ធ្នូ សម្តេច សីហនុ បានប្រកាសពីទីក្រុងប៉េកាំងថា ព្រះអង្គត្រៀមខ្លួន ដើម្បី ត្រឡប់ទៅតស៊ូនៅលើទឹកដីខ្មែរ។ នៅថ្ងៃទី២៧ ធ្នូ លោក ខៀវសំផន ត្រូវបានតែងតាំងជា រដ្ឋមន្ត្រីទី១ នៃកម្ពុជាប្រជាធិ

បតេយ្យ ជំនួសលោក ប៉ុល ពត, តែ ប៉ុល ពត នៅរក្សាមុខងារជាអគ្គមេបញ្ជាការកងទ័ព។

ត្រូវដឹងថា ក្រោយពីបរាជ័យ ក្រុមខ្មែរក្រហម បានប្រមូលផ្តុំទាហ៊ានខ្លួនបានឡើងវិញ មានចំនួនប្រមាណ ២ម៉ឺននាក់[31]។ ចំណែកលោក សឺន សាន បានប្រមូលជនភៀសខ្លួនខ្មែរ[32] នៅតាមជុំរុំតាមព្រំដែន ខ្មែរ-ថៃ អោយស្ម័គ្រចូលធ្វើទាហ៊ានតស៊ូ បានចំនួន ប្រមាណជាង ១ម៉ឺននាក់។ ទីតាំងតស៊ូ របស់រណសេរ្ស របស់លោក សឺន សាន ស្ថិតនៅជុំរុំ សាយធូ (site 2) នៅជាយដែន ខ្មែរ-ថៃ។

[31] មុនកងទ័ពខ្មែរក្រហម ត្រូវទ័ពយួនវាយបែក កងទ័ពនេះមានចំនួន ២៣ កងពលធំ (ចំនួនទាហ៊ានប្រមាណ ២០ម៉ឺននាក់) ដែលមានចិនតែមួយគត់ ជាអ្នកផ្តល់ នូវអាវុធយុទ្ធភណ្ឌគ្រប់បែបយ៉ាងដល់កងទ័ពនេះ។

[32] នៅពេលកងទ័ពយួន វាយលុកចូលស្រុកខ្មែរ មានខ្មែរជាច្រើនម៉ឺននាក់នាំគ្នារត់មកប្រទេសថៃ ដោយយល់ឃើញថា យួន ក៏ជាកុម្មុយនិស្ត ដូច ខ្មែរក្រហមដែរ។

## ការរំឭកអំពី ការតស៊ូ របស់លោក សឺន សាន

ក្រោយពី ពួកខ្មែរក្រហម ទទួលបាន នូវជ័យជំនះនៅឆ្នាំ ១៩៧៥, នៅឆ្នាំ ១៩៧៦ លោក បានបង្កើតសមាគមមួយ នៅស្រុកបារាំង ឈ្មោះថា សមាគមខ្មែរទូទៅនៅបរទេស ក្នុងគោលបំណងប្រមូលកម្លាំងខ្មែរតែមួយ ដែលកំពុងរស់ នៅបរទេស ដើម្បីជួយទ្រទ្រង់ ចលនាតស៊ូផ្សេងៗមួយ ចំនួន នៅជាយដែន ខ្មែរ-ថៃ ប្រឆាំងនឹងរបបខ្មែរក្រហម, ដូចមាន ចលនាលោក ព្រុំវិត, កេត រ៉េត, តាម៉ាំង (លឿង ស៊ីណាក់), កែវ ជួន និង អ៊ឹម ឈូដេត...។ល។ បាវចនា របស់ សមាគមគឺ « យើងរួបរួមគ្នា ដើម្បីបំរើបងប្អូនប្រុសស្រី របស់យើង »។ នៅឆ្នាំ ១៩៧៩ ក្រោយពីប្រទេសកម្ពុជា ត្រូវ បានកងទ័ពហាណូយឈ្លានពានហើយ លោក ឧត្តមសេនី យ គ្រៀងសាក់ ចូម៉ាណង់ កាលនោះជានាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រថៃឡងដ៍ (តាមការណែនាំពីលោក លែ គុក-ទុយ និង លោក វរសេនីឯក អ៊ឹម ឈូដេត) បានចាត់ លោក វរសេនីយឯកសៀម ឆាវ៉ាលិត យុងឆៃយុទ្ធ មកជួប លោក សឺន សាន នៅទីក្រុងប៉ារីស ហើយ អញ្ជើញលោក ទៅធ្វើទស្សកិច្ច នៅតាមដំបន់ជាយដែនថៃ ដើម្បី បង្កើត

ចលនាមួយ ប្រឆាំងនឹង ពួកយួនឈ្លានពាន។ ក្រោយពីទទួលដំណឹងនេះ ពួកខ្មែរក្រហមបានស្នើដល់លោក សឺន សាន អោយបង្កើតជា មហារណសេរ្ស ដែលមានពួកគេចូលរួបរួមផង។ លោក សឺន សាន បានយកសំណើរនេះ មកស្នើដល់ ក្រុមទាហ៊ាន និង ក្រុមស៊ីវិល ជាពិសេសក្រុមនារី ដែលគាំទ្រលោក តែពួកទាំងនោះបានសុំអោយលោក បដិសេធនូវសំណើនេះ។ ប៉ុន្តែ លោក សឺន សាន បានស្នើតបទៅពួកខ្មែរក្រហមវិញថា បើពួកគេសុខចិត្តដកចេញ សមាសភាពមេដឹកនាំគេមួយចំនួន ដូចជា លោក ប៉ុល ពត, នួន ជា, តាម៉ុក និង អៀង សារី, លោក នឹងអាចលើកសំណើរនេះ មកសិក្សារួម ជាមួយពួកខ្មែរក្រហម។ តែពួកនោះ គេមិនសុខចិត្តយល់ព្រម នូវលក្ខខណ្ឌបែបនេះ។ អំណើះមកទៀត នៅឆ្នាំ ១៩៨១, សម្តេច សីហនុ មានព្រះទ័យ បង្កើតរណសេរ្សតស៊ូមួយ មានឈ្មោះថា រណសេរ្សបង្រួបបង្រួមជាតិ ដើម្បីកម្ពុជា ឯករាជ្យ អព្យាក្រឹត្រ សន្តិភាព និង សហ

ការណ៍[33]។ បន្ទាប់មក ព្រះអង្គ បានបង្កើត កងទ័ពជាតិនិយមសីហនុ។ កងទ័ពនេះ មានជំនួនទាហ៊ានប្រមាណ ៥ ពាន់នាក់ គឺជាការប្រមូលផ្តុំ ក្រុមតស៊ូមួយចំនួន ដែលតាំងខ្លួនជាអ្នករាជានិយម នៅក្នុងចំណោមនោះ មានក្រុមតស៊ូធំជាងគេមួយ ឈ្មោះ មូលិការ ដឹកនាំដោយអតិតនាយទាហ៊ានជើងទឹក ឈ្មោះ គង់ ស៊ីលាស់។ ក្រោយពីលោក គង់ស៊ីលាស់ ទទួលមរណភាព នៅឆ្នាំ ១៩៨១[34] លោក អ៊ិន តាំ មកធ្វើជំនួស តែលោក បានលាលែង នៅឆ្នាំ ១៩៨៥។

នៅចំពោះមុខ កងទ័ពយួន កាន់កាប់ស្រុកខ្មែរ ចំនួន ពីរសែននាក់, កងទ័ពតស៊ូខ្មែរ ទាំងបីក្រុម នៅឆ្នាំ ១៩៨១ សម្រេច បង្កើត គណកម្មការពិសេស ដើម្បី សិក្សារួម អំពី

---

33 ហ៊្វុនស៊ិនប៉ិច (Funcinpec) : Front uni national pour un Cambodge indépendant, neutre, pacifique et coopératif.

34 លោក គង់ ស៊ីលាស់ ជាអតីតវរសេនីឯកនាវី ជំណាន់សម័យសាធារណរដ្ឋខ្មែរ។ មានពាក្យចចាមអារ៉ាមថា គាត់ស្លាប់ដោយមានគេបំពុល, អ្នកនោះគឺលោក ជា ឈុត ជាអនុប្រធាន របស់គាត់ នៅជំរុំ ណង ចាន់។ អ្នកខ្លះទៀតថា ស្លាប់ដោយជម្ងឺគ្រុនចាញ់។

ការបង្កើត រណសិរ្សរួម។ បន្ទាប់មកទៀត នៅខែកញ្ញា ឆ្នាំ ១៩៨១ នៅទីក្រុង បឹងកក នៅប្រទេសថៃ មានការជួបប្រជុំ ជាផ្លូវការ នៃចលនាតស៊ូខ្មែរទាំងបី អស់រយៈពេលបីថ្ងៃ (ថ្ងៃទី ១៣, ១៨ និង ២២ កញ្ញា) ដើម្បីសម្រាំង គំរោងការណ៍បង្កើតរដ្ឋាភិបាលត្រីភាគី ហើយ ត្រូវបានប្រកាស នៅថ្ងៃទី១៦ មិថុនា ឆ្នាំ ១៩៨២ ដែលមានសម្តេច សីហនុ ជាប្រធាន, លោក ស៊ីន សាន ជា រដ្ឋមន្ត្រីទី១ និង លោក ខៀវ សំផន ជា អនុប្រធាន ទទួលបន្ទុក កិច្ចការបរទេស។ រដ្ឋាភិបាលថ្មីនេះ នៅបន្តកាន់ទង់ជាតិ របស់ កម្ពុជាប្រជាធិបតេយ្យ ដើម្បី រក្សាកៅអី នៅអង្គការសហប្រជាជាតិ ហើយ ដឹកនាំការតស៊ូប្រដាប់អាវុធ ដើម្បី រំដោះស្រុកខ្មែរ ពីការកាន់កាប់កងទ័ពយួន[35]។ ពីដើមទី សម្តេច សីហនុ

35 ដើម្បីសម្រួល នូវការបង្កើតនេះ ក្រុមខ្មែរក្រហម ប្រកាសរំលាយ គណបក្សកុម្មុយនិស្តខ្មែរ របស់ខ្លួន ដែលក្រុមសម្តេច សីហនុ និង លោក ស៊ីន សាន ទុកជា របងមនោគមវិជ្ជា ចំពោះពួកខ្លួន។ ការបង្កើត រណសិរ្សរួម និង រដ្ឋាភិបាលត្រីភាគី នេះ ជា គោលបំណង របស់ ចិន អាមេរិកាំង និង អាស៊ាន (ASEAN) ដើម្បីបង្រឹងកម្លាំងតស៊ូប្រឆាំងនឹង កងទ័ពយួន កាន់កាប់ស្រុកខ្មែរ។

ទ្រង់មិនព្រះសុភចិត្តនឹង គំនិត បង្កើត រណសិរ្សរួម និង រដ្ឋាភិបាលត្រីភាគីនោះឡើយ ហេតុនេះឯង នៅឆ្នាំ ១៩៨០ បានជាព្រះអង្គ មិនយាង តាមការអញ្ជើញ របស់លោក Lee Kuan Yew ទៅប្រទេសសិង្ហបុរី ដើម្បីជួបពិភាក្សាជាមួយ លោក ខៀវ សំផន និង ស៊ឺន សាន អំពីគំរោងការណ៍នេះ។ ព្រះអង្គ ថែមទាំងយល់ឃើញថា វាជា ការឃុបឃិតមិនល្អ របស់ ចិន និង អាមេរិកាំង ដូច្នេះ ព្រះអង្គ មិនចង់ធ្លាក់ចុះទៅក្នុងនោះទេ។ តែក្រោយមក ព្រះអង្គ ប្ដូរព្រះរាជហឫទ័យ ប្រាប់កាសែតអាឡឺម៉ង់ Der Spiegel ចុះផ្សាយនៅថ្ងៃទី ៩ មិថុនា ឆ្នាំ ១៩៨១ ថា ព្រះអង្គប្ដូរចិត្ត ព្រោះចិនគេទទូចសូមឲព្រះអង្គ ចូលរួមបង្កើត។

នៅស្រុកខ្មែរ ហាណូយ ជួបប្រទះ នូវបញ្ហា មិនសហការ ពីសំណាក់ប្រជាជនខ្មែរ តែ ដោយសារ ខ្មែរ ខ្លាច នូវការវិលត្រឡប់ នៃរបបខ្មែរក្រហម ក៏មិនប្រឆាំងនឹងវត្តមានកងទ័ពខ្លួននោះដែរ។ ម្យ៉ាងមួយទៀត យួន គេមិនសូវមានការទុកចិត្ត ទៅលើ អ្នកដឹងនាំខ្មែរ ដែលគេតែងតាំងនោះដែរ ដូច្នេះ យួន គេដឹកនាំស្រុកខ្មែរ ផ្ទាល់តែម្ដង នៅពី

ក្រោយរបាំងមុខ នៃសាធារណរដ្ឋ ប្រជាមានិតកម្ពុជា[36]។ រដ្ឋការខ្មែរ ដែលយួន គេបង្កើតឡើង គឺមានតួនាទីត្រឹមតែជា អ្នកជំនួយ ថ្នាក់ អ្នកបំរើការ សុទ្ធសាធ។ កងទ័ពយួន ក្រោយពីវាយ ចូលកាន់កាប់ ទីក្រុងធំៗ និង ស្រុកធំៗបានមួយចំនួនក្រែល ហើយនិង ផ្លូវជាតិសំខាន់ៗ តែជនបទ វិញ ទ័ពយួន នៅមិនទាន់មានលទ្ធភាព អាចត្រួតត្រាបាននៅឡើយ ព្រោះ កងឯកភាពខ្មែរក្រហម និងក្រុមតស៊ូតូចៗមួយចំនួន ប្រឆាំងខ្មែរក្រហម កាលវានៅកាន់អំណាច នៅធ្វើសកម្មភាពទ័ពព្រៃនៅឡើយ តែបែរមុខប្រឆាំងយួនវិញ ដូចខ្មែរក្រហមបាក់ទ័ព វាយដោះខ្លួនពីយួន។ ដើម្បី ប្រឈរមុខនឹងបញ្ហានេះ ទ័ពយួន សម្រេចប្រមូលផ្តុំ កងទ័ព នៅតែខាងលិច នៃទន្លេមេគង្គ។ យុទ្ធសាស្ត្រ អាចឲទ័ពយួន កាន់កាប់ពេញលេញ ២/៣ នៃដែនដីខ្មែរ ដែល យួនគេទុកជា ដែនដីភ្ជាប់រួចស្រេច នឹងស្រុក

[36] ឈ្មោះរបប ដែលយួនគេបង្កើតនៅកម្ពុជា។ របបនេះនៅក្រោមការត្រួតត្រា នៃគណបក្ស ប្រជាមានិត បដិវត្តន៍ នៃកម្ពុជា ដែលជាបក្ស រណប បក្សកុម្មុយនិស្តយួន។

យួន។ ចំណែក ដំបន់ខាងកើត នៃទន្លេមេគង្គ ជាដែនដីយួនកាន់កាប់ ហើយបន្ត នយោបាយ ត្រួតត្រាស្រុកខ្មែរទាំងមូល នៅពេលអនាគតដ៏ខ្លីមួយ។ ត្រូវដឹងថា នៅសម័យកម្ពុជាប្រជាធិបតេយ្យ របបនេះ មិនដែលត្រួតត្រាដែនដី នៅខាងលិច នៃទន្លេមេគង្គ ទាំងមូលបាននោះឡើយ ព្រោះនៅមាន កងទ័ពយួនកាន់កាប់ នៅតាមបណ្តោយព្រំដែន ខ្មែរ-យួន ក្រោយពីស្រុកយួន ក្លាយជាស្រុកតែមួយ ដែលនាំបង្កើតបញ្ហាព្រំដែន ខ្មែរ-យួន ដែលយើងបានរៀបរាប់ខាងលើរួចហើយ។ នៅថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ១៩៨០ ទ័ពយួន បើកការវាយលុក ជុំរុំ នៃជនភៀសខ្លួនខ្មែរនៅក្នុងស្រុកសៀម ដែលត្រួតត្រាដោយ ពួកខ្មែរតស៊ូមិនមែនកុម្មុយនិស្ត នៅខាងជើង នៃខេត្ត Aranya Prathet នៅក្នុងភូមិ Non Mak Mun[37]។ បន្ទាប់មក កងទ័ពយួន បែរវាយ នៅពាក់កណ្តាលខែ កក្កដា មូលដ្ឋានមាំ

---

37 ចំពោះយួន ភូមិនេះ ជាមូលដ្ឋាន របស់ក្រុមពិសេស របស់អាមេរិកាំង ធ្វើសកម្មភាព វិទ្ធស្សនាប្រឆាំង យួន និង សាធារណរដ្ឋប្រជាមានិតកម្ពុជា។

របស់ពួកខ្មែរក្រហម នៅ ភ្នំម៉ាឡៃ បែកខាងត្បូង នៃខេត្ត Aranya Prathet តែនៅក្នុងដែនដីខ្មែរ។ ការបើកវាយលុកប្រហារនេះ ធ្វើឡើង នៅរដូវវស្សា នាំឲមានការភ្ញាក់ផ្អើល នៃពួកសង្កេតការ តែ បន្ទាប់មក គេដឹងថា យួនមានគោលដៅបីយ៉ាង : ១. វាយឃាំង កុំអោយ សៀម ប្រមូលជនភៀសខ្លួនខ្មែរស្ម័គ្រចិត្ត មករស់នៅជុំរុំ សាកែវ នៅក្នុងដែនដីសៀម ដែលយួនមានការសង្ស័យថា យកមកពង្រឹងកម្លាំងតស៊ូ របស់ពួកខ្មែរក្រហម, ២. បញ្ឈប់ ការផ្គត់ផ្គង់ពស្តុភា និង ស្បៀង តាមព្រំដែន ខ្មែរ-សៀម របស់កងកម្លាំងតស៊ូខ្មែរ, ៣. វាយបោសសំអាត ជំរុំតស៊ូខ្មែរមួយចំនួន តាំងនៅព្រំដែន ខ្មែរ-សៀម។

នៅឆ្នាំ ១៩៨៤-៨៥ កងទ័ពយួន និង ខ្មែររណបយួន បើកការវាយលុកយ៉ាងធំ នៅតាមព្រំដែន ខ្មែរ-សៀម ម្តងទៀត ហើយ យួន ទុកជាជោគជ័យ ហើយធ្វើការប្រកាស នៅឆ្នាំ ១៩៨៥ ថាដកទ័ពខ្លួនមួយផ្នែកចេញពីកម្ពុជា មានចំនួន ១៥ ០០០ នាក់។ ដោយស្របគ្នា លោក ង្វៀង កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេយួន និង លោក មច្ចតា រដ្ឋមន្ត្រីក្រសួងការបរទេស ឥណ្ឌូណេស៊ី បានជួបចរចាគ្នា ដើម្បី រកដំណោះ

ស្រាយសង្គ្រាមនៅកម្ពុជា តាមសន្តិវិធី។ យួន ដាក់លក្ខខណ្ឌចាំបាច់ របស់គេ គឺ ការចរចាផ្ទាល់ រវាងយុទ្ធការីខ្មែរ ពាក់ព័ន្ធនឹងសង្គ្រាម នៅក្នុងរូបមន្តមួយ ដែលគេឲឈ្មោះថា COCTAIL PARTY MEETING។ លក្ខខណ្ឌនេះ គឺយួនមានគោលបំណង ប្តូររូបសង្គ្រាមឈ្លានពានយួន អោយទៅជាសង្គ្រាម រវាងខ្មែរនិងខ្មែរ។ បន្ទាប់មក មានជំនួប លើកទី១ ក្រៅផ្លូវការ អស់រយៈពេល បីថ្ងៃ ចាប់ផ្តើមពីថ្ងៃទិ២ ធ្នូ ឆ្នាំ ១៩៨៧ រវាង សម្តេច សីហនុ និង លោក ហ៊ុន សែន នៅប្រទេសបារាំង នៅភោជនីយដ្ឋាន នៅភូមិ FERE-EN-TARDENOIS។ តែនៅលើសមរភូមិវិញ សង្គ្រាម នៅមានដដែល ទោះបីមានការចំរើន នៃកិច្ចការទូតមមាញឹក លើឆាកអន្តរជាតិក៏ដោយ។ នៅក្នុងរយៈពេលនោះ សម្តេចសីហនុ បានប្រកាសលាលែងពីមុខដំណែង ប្រធានរដ្ឋាភិបាលត្រីភាគី នៅថ្ងៃទី៨ វិច្ឆិកា ឆ្នាំ ១៩៨៨។ ការលាលែងនេះ ជាល្បែង របស់ព្រះអង្គ ដូចសព្វដង នៅក្នុងឆាកនយោបាយ គឺ ចិត្តសាវ៉ា របស់ព្រះអង្គ ព្រោះ បន្ទាប់ពីជំនួប សម្តេច សីហនុ ជាមួយ លោក ហ៊ុន សែន ទ្រង់ត្រូវបានយួន ក្តាប់ព្រះអង្គបានរួចស្រេច។ ទោះបីក្រោយមក

ព្រះអង្គ វិលត្រឡប់មកមកកាន់តំណែងវិញក៏ដោយ តែ ទ្រង់ បានត្រៀមខ្លួនរួចរាល់ហើយ នឹងចុះចូលរបបភ្នំពេញ ព្រោះ ទេយ្យទានយួន ថ្វាយដល់ព្រះអង្គ វាស្របនឹងការរង់ចាំដ៏យូរកាលមកហើយ របស់ព្រះអង្គ គឺ រាជបល្ល័ង។ ចំពោះ សម្តេច សីហនុ ការតស៊ូ រំដោះជាតិ របស់ទ្រង់ វាចប់សព្វគ្រប់ពីពេលនោះមកម្លេះ។ ព្រឹត្តិការណ៍បន្ត រហូតមកដល់ការចុះហត្ថលេខា នៃកិច្ចព្រមព្រៀងសន្តិភាព វាគ្រាន់តែជា ការលាក់ពុតរបស់យួន បោក សហគមន៏អន្តរជាតិ ឲ ទទួលស្គាល់ ភាគីរបណខ្លួនជាផ្លូវការ និង ឈប់ផ្តន្ទាទោស និងដកទណ្ឌកម្មសេដ្ឋកិច្ច ដល់អំពើឈ្លានពាន របស់ខ្លួន តែប៉ុណ្ណោះ។ ត្រូវដឹងថា គ្រប់កិច្ចព្រមព្រៀងអន្តរជាតិ យួនកុម្មុយនិស្ត មិនដែលគោរពម្តងណាឡើយ។ យួនប្រកាស ដកទ័ពចេញពីស្រុកខ្មែរ តែទាហ៊ានយួន វាបញ្ចូល នៅក្នុង កងទ័ពខ្មែររណបវារួចស្រេចហើយ និង លាក់ខ្លួន នៅក្នុង

និគមជនយួន រស់នៅស្រុកខ្មែរ[38]។ ហេតុនេះឯង ក្រោយពីការបោះឆ្នោត នៅឆ្នាំ ១៩៩៣ យួនមិនខ្លាចចោភាគីរណបខ្លួន មិនទទួលស្គាល់លទ្ធផល នៃការបោះឆ្នោត ហើយគំរាម ផ្ញើអបគមន៍ស្រុកខ្មែរ ដែលនាំឲសម្តេច សីហនុដើរតួជាអ្នកស្នើបង្កើត រដ្ឋាភិបាលក្បាលពីរ ដែលនាំឲវាមានកម្មវិបាក ដល់ប្រជាជាតិខ្មែរ រហូតមកដល់សព្វថ្ងៃនេះ។ ដូច្នោះ សម្តេច សីហនុ ព្រះអង្គ ជាសិប្បករ នៃវិនាដកម្មខ្មែរ តាំងពីព្រះអង្គ ចូលបំរើ ចិន និង យួន កុម្មុយនិស្តចាប់តាំងពីទសវត្ស ៦០។

[38] UNTAC គ្មានលទ្ធភាព ត្រួតពិនិត្យ ការដកទ័ពយួន ចេញពីស្រុកខ្មែរ។ ដូច្នេះ យួននៅតែរក្សាកម្លាំងទ័ព ដើម្បីការពារភាគីខ្មែររណបខ្លួន រហូតមកដល់សព្វថ្ងៃនេះ។



## សេចក្តីសន្និដ្ឋាន

វិធី របស់ពួកកុម្មុយនិស្ត ដែលធ្វើឲ សត្រូវនៅតែលតោល គឺ ម្យ៉ាងបំបែងបំបាក់ ម្យ៉ាងទៀតចងសម្ពន្ធមិត្ត។ វិធី បំបែកបំបាក់កម្លាំងសត្រូវ គឺទាញយក សត្រូវដែលបែក ចេញ មករួម ជាមួយជាកម្លាំង។ វិធីនេះឯង ដែលយួន កុម្មុយនិស្ត គេយកមកអនុវត្តនៅស្រុកខ្មែរ ប្រកបដោយ ជោគជ័យ។

## វិធីបំបែកបំបាក់

ការបំបែកបំបាក់រួមមាន :

- បំបែកបំបាក់ ខាងផ្លូវចិត្ត « មនោគមវិជ្ជា » គឺធ្វើឲ សត្រូវជ្រួលច្របល់ ខូចឯកភាព។
- បំបែកបំបាក់ អង្គការ ដូចជាធ្វើឲមាន ការបះបោរ « ប្រឆាំងក្នុងផ្ទៃខ្នាំង »។
- បំបែកបំបាក់ វណ្ណៈ ដូចធ្វើជាប្រឌិតឲមានវណ្ណៈ។
- បំបែកបំបាក់ សាសនា ថាអ្នកនេះកាន់សាសនានោះ អ្នកនោះកាន់សាសនានេះ, សាសនានេះអាក្រក់ ឬ

សាសនានោះល្អជាង គឺធ្វើឲ្យអ្នកកាន់សាសនាឈ្លោះគ្នា។

**វិធីចងសម្ពន្ធមិត្ត**

នៅខែមិនា ឆ្នាំ ១៩២៦ ពេលធ្វើសំយោគ ពីវណ្ណៈនិមួយៗនៃសង្គមចិន លោក ម៉ៅ គាត់ចែកមនុស្សជាបីពួកគឺ :

- ពួកជឿនលឿន ឆ្វេងនិយម មាន : កម្មករ (វណ្ណៈអធន) ពួកបញ្ញាវ័ន្តឆ្វេងនិយម ;
- ពួកកណ្តាល មាន : កសិករមធ្យម, អ្នកតូចតាច, អ្នកបញ្ញាវ័ន្ត, អ្នកមានដីធ្លីតិចតួច និង បក្ស ដែលមិនប្រឆាំងនិងកុម្មុយនិស្ត ;
- ពួកកុម្មុយនិស្ត បរិសុទ្ធ។

ដូច្នេះ ពួកកុម្មុយនិស្តយល់ថា ដើម្បីឈ្នះ ត្រូវដណ្តើមយកពួកនិយមកណ្តាលឲបាន គឺ :

- បង្កើតកម្លាំងឆ្វេងនិយម ;
- គោរពផលប្រយោជន៏ ដល់ពួកកណ្តាលនិយម ;
- វាយសំពងឲខ្លាំងពួកស្តាំនិយម។

ពួកកុម្មុយនិស្ដ គេតែងនិយាយ ទុកជាគោលការណ៍ថា « សម្ព័ន្ធមិត្ត ជាមួយពួកឆ្វេងនិយម ទាញពួកកណ្ដាល ហើយ សំពងពួកស្ដាំនិយម »។

នៅស្រុកខ្មែរ ក្នុងទសវត្ស ៦០ ពួកជឿនលឿន អ្នកឆ្វេងនិយម គឺ ភាគច្រើន មាននៅក្នុងមជ្ឈដ្ឋាន គ្រូបង្រៀនបឋមសិក្សា និង សាស្ត្រាចារ្យវិទ្យាល័យ, ចំណែក មន្ត្រីរាជការភាគច្រើន ជាអ្នកស្ដាំនិយម ជាតិនិយម, រីឯ យុវជន វិញ គឺ ជាអ្នកសីហនុនិយម។ កម្មករ, កសិករ និង សហធម្មិកពុទ្ធសាសនា ជា អង្គនយោបាយកណ្ដាល។ ពីដើមទី ពួកយួនកុម្មុយនិស្ដ មានការពិបាកនឹង អនុវត្ត វិធីវាយបំបែងបំបាក់សង្គមខ្មែរ ទោះបី សង្គមនេះ មានរចនាសម្ព័ន្ធមានគ្រោងទុកនៅក្នុងទ្រឹស្ដីកុម្មុយនិស្ដ ព្រោះ សង្គមខ្មែរ មិនមានសារជាតិ ជាសង្គម បរិបដិវត្តន៍ ជាពិសេស បដិវត្តន៍ តាមគន្លង លទ្ធិកុម្មុយនិស្ដ។ ម្យ៉ាងទៀត ពួកអ្នកដឹកនាំបដិវត្តន៍ គឺ ជាជនជាតិយួន ព្រោះជនខ្មែរ តែងតែទុកនៅក្នុងចិត្ត ជាតិសាសន៍យួន ជាសត្រូវប្រវត្តិសាស្ត្រ។ ដូច្នោះ បក្សកុម្មុយនិស្ដខ្មែរ ដែលពួកយួនកុម្មុយនិស្ដ ជាអ្នកបង្កើត មិនអាចទាញសមានចិត្ត ពីជនខ្មែរបាន

ច្រើនឡើយ។ ដូច្នោះ បក្សកុម្មុយនិស្តយួន ត្រូវចាំបាច់ប្តូរយុទ្ធសាស្ត្រ ប្រើការទូត ដើម្បី ចងសម្ពន្ធមិត្ត ហេតុជាឱកាស (alliance occasionnelle) ជាមួយ សម្តេច សីហនុ ព្រោះ ព្រះអង្គ មានសត្រូវរួម គឺ សហរដ្ឋអាមេរិក និង មានមិត្តរួម គឺ ចិនប្រជាមានិត ជាមួយគេ។ ដូច្នេះ បក្សកុម្មុយនិស្តយួន បានបញ្ជា ឲបក្សកុម្មុយនិស្តខ្មែរ ដែលយួន គេទុកជា សម្ពន្ធមិត្ត ជានិច្ចកាល (alliée permanent) របស់គេ ឲបន្ថយសិន នូវសកម្មភាពនយោបាយបដិវត្តន៍នៅស្រុកខ្មែរ ព្រោះវានាំរំខានដល់ការតស៊ូ របស់គេនៅស្រុកយួនខាងត្បូង។ តែនៅឆ្នាំ ១៩៦៦ មានរាជរដ្ឋាភិបាលថ្មីដឹកនាំដោយលោក ឧត្តមសេនីយ លន់ នល់ ដែលមាននិន្នាការស្តាំនិយម ហើយ ទប់ទល់ មិនអោយកសិករ លក់ស្រូវឲយៀកកុង ដែលជានយោបាយ រំខានដល់ប្រយោជន៍យួនកុម្មុយនិស្ត, ពួកយួន គេប្តូរកលល្បិច ញុះញង់ឲពួកខ្មែរកុម្មុយនិស្ត ដែលសម្តេច សីហនុ ហៅថា « ខ្មែរក្រហម » ធ្វើ វិទ្ធង្សនា ដូចយ៉ាងនៅខែកុម្ភៈ ឆ្នាំ ១៩៦៧ ពួកនោះបោះខិតបណ្ណ រិះគន់ នយោបាយ របស់សម្តេច សីហនុ នៅពេលដែលព្រះអង្គយាងទៅ ព្យាបាលរោគ នៅប្រទេសបារាំ

ង។ គោលបំណង របស់ពួកកុម្មុយនិស្តនៅពេលនោះ គឺចង់បង្កើត វិបត្តិនយោបាយ ដើម្បី រំលំ រដ្ឋាភិបាលលោក លន់ នល់ ដែលពួកគេ ទុកជាគ្រោះថ្នាក់ដ៏ធំមួយ ដល់ប្រយោជន៏គេ។ បីថ្ងៃបន្ទាប់ពីសម្តេច សីហនុ យាងវិលត្រឡប់ចូលស្រុកវិញ នៅថ្ងៃទី១១ មីនា លោក ខៀវ សំផន បានដឹកនាំបាតុកម្មមួយ នៅទីក្រុងភ្នំពេញ ដើម្បី សំដែងការគាំទ្រនយោបាយ របស់សីហនុ តែតាមពិតគឺ ទាមទារឲលោក លន់ នល់ លាលែងពីតំណែងនាយករដ្ឋមន្ត្រី។ ដើម្បី ដុតភ្លើងវិបត្តិនយោបាយ ឲកាន់តែឆេះខ្លាំងឡើង ពួកខ្មែរក្រហម និង ខ្មែរយៀកម៉ិញ នាំគ្នាញុះញង់ដល់ ពួកកសិករ នៅភូមិសំឡូត នៅខេត្ត បាត់ដំបង ឲបះបោរប្រឆាំងនឹង រដ្ឋាភិបាលលោក នល់ នល់ ហើយទាមទារសូមឲសម្តេច សីហនុ ដឹកនាំរដ្ឋាភិបាល ជំនួសលោក លន់ នល់។ ជា ចៃដន្យ លោក លន់ នល់ គាត់មានគ្រោះក្រឡាប់រថយន្តនៅខេត្តកោះកុង[39] បន្ទាប់មកលោក បានដាក់ពាក្យ

---

[39] នៅក្នុងរថយន្ត Jeep យោធានោះ មានមនុស្សជិះបីនាក់ : លោក លន់ នល់, ឃឹក ជូឡុង នៅពេលនោះជា អគ្គមេបញ្ញាការ និង អគ្គ

សូមលាលែងពីតំណែងទៅ។ សម្តេច សីហនុ ទ្រង់បង្កើតរដ្ឋាភិបាលពិសេស ដឹកនាំដោយព្រះអង្គផ្ទាល់ ដើម្បីដោះស្រាយបញ្ហាមានកើតឡើងនៅភូមិសំឡូត។ ដំណោះស្រាយដាច់ខាត របស់ព្រះអង្គ គឺនៅខែមិថុនា ទ្រង់បញ្ជាឲកងទ័ពអាកាស ទំលាក់គ្រាប់បែកទៅលើ ភូមិបឹងឃ្មុំថ្វាក់ និងឬសីព្រះ ដែលជាទីកន្លែង ដែលពួកអ្នកភូមិសំឡូត រត់ទៅពួន នាំឲស្លាប់ប្រជារាស្ត្រជាច្រើន។ នៅឆ្នាំដដែលនោះដែរ សម្តេច សីហនុ បាន ក៏បញ្ជាឲតុលាការយោធា កាត់ទោសប្រហារជីវិត ពួកខ្មែរសេរី ដែលសូមចុះចូលនឹងព្រះអង្គ ដូចយ៉ាង លោក ថៅ បូរី ថៅ មាធូរា (ជាបងប្អូនបង្កើត) និង សៅ ង៉ុយ។ អ្នកទាំងបី ត្រូវបានប្រហារជីវិត តាមវិធីបាញ់សម្លាប់ជាសាធារណៈ នៅត្រពាំងក្រឡឹង។ សម្តេច សីហនុ ឲថតកុន ហើយ ឲយកទៅបញ្ចាំង នៅតាមសាលារៀន គ្រប់ថ្នាក់ ដើម្បីឲ កុមារាកុមារី និង សិស្សានុសិស្ស មើលទុកជា

---

នាយសេនាធិការ នៃកងខេមរៈភូមិន្ទ, ឧប គឹម អាង នៅពេលនោះជា រដ្ឋមន្ត្រីក្រសួងការពារជាតិ។ លោក ញឹក ជូឡុង ជាអ្នកបើករថយន្ត។ លោក លន់ នល់ មានគ្រោះថ្នាក់បាក់ជើង រីឯ អ្នកពីរនាក់ទៀត គ្មានរបួសអ្វីនោះឡើយ។

មេរៀនថា ពួកអ្នកប្រឆាំងនឹងព្រះអង្គ នឹងប្រកដជាជួប វាសនាអាក្រក់បែបយ៉ាងនេះឯង។ នេះឯងហើយ ជាភាព ឃោឃៅ របស់សីហនុ។ ទោះបីចាប់ពីឆ្នាំ ១៩៦៨ សម្ដេច សីហនុ ស្វែងរកទំនាក់ទំនងជាថ្មី ជាមួយសហរដ្ឋអាមេរិក ដើម្បី រកសមតា នៃនយោបាយទ្រង់ រវាង លោកកុម្មុយ និស្ត និង លោកសេរី តែការស្ម័គ្រចិត្ត របស់ព្រះអង្គ ទៅរក ចិន និង យួនកុម្មុយនិស្ត វាមកដល់ដំណាក់ការមួយ ដែល វាលែងអាច វិលត្រឡប់ក្រោយវិញបាននោះហើយ រហូត មានកើតព្រឹត្តិការណ៍ ១៨ មីនា ឆ្នាំ ១៩៧០ ដែលនាំផ្ទុះស ង្គ្រាមឈ្លានពានពីសំណាក់យៀកកុងនៅស្រុកខ្មែរ។

សង្គ្រាម វាជាអំពើហិង្សា។ គូសត្រូវម្នាក់ៗ ចង់ឈ្នះលើគូស ត្រូវខ្លួន ប្រើ ហិង្សា ពោលថា ហិង្សាពលំ ជាមធ្យោបាយមួយ នៅទីបញ្ចប់គឺ សំរាប់បង្ខំ ការចង់បាន របស់ខ្លួន។ តែ ស ង្គ្រាម រវាង អារ្យៈប្រទេស វាមានភាពឃោឃៅ តិចជាង ស ង្គ្រាម រវាង ក្រុមមនុស្សព្រៃ ដ្បិត មូលហេតុជាជម្រៅ របស់ សង្គ្រាម គឺ បំណង នៃប្រទូសភាព មិនមែន ជា អារម្មណ៍ នៃប្រទូសភាព នោះឡើយ។ សព្វដង នៅពេលដែល បំណង ជម្លោះ រវាងគូវិវាទ មានកើតឡើង, កិលេស ទោសៈ វាមិន

យូរឡើយនឹង ពន្ធ្យុះពួកអ្នកប្រយុទ្ធ ជាពុំខាន។ តែ បើតាមទ្រឹស្តី នៅក្នុងសង្គ្រាមជំមួយ វាអាចគ្មាន ទោសៈ បានព្រោះ ជាសង្គ្រាម រវាងអារ្យៈជន ពាក់ឯកសណ្ឋានជាយុទ្ធជន ដែល តែងតែយក បញ្ញា ជា សីលគន្ធ របស់ខ្លួន ជាងការសំដែង នៃសភាវគតិ។ ដូច្នេះ គោលបំណង នៃការកំទិចគូសត្រូវ វាតែងទប់ដោយ ការរីកចំរើន នៃមនុស្សធម៌។ ដូច្នោះ គោលដៅសង្គ្រាម គឺកំទិចតែអាវុធ របស់សត្រូវឲអស់គ្មានសល់ ដើម្បីកុំឲសត្រូវអាចប្រើ វាយតតាំងនឹងខ្លួនបានទៀត។ ចំពោះពួកកុម្មុយនិស្ត គេមានទស្សនៈ នៃសង្គ្រាម ខុសពីទស្សនៈ ខុសពីខាងលើ, សង្គ្រាម ចំពោះគេគឺ មិនត្រឹមតែវាយកំទិចអាវុធសត្រូវតែប៉ុណ្ណោះទេ គឺ កំទិចធម្មជាតិ នៃមនុស្ស ដើម្បីឲមនុស្សក្លាយជាឧបករណ៏នៃបក្សកុម្មុយនិស្ត ដើម្បី ប្រើសំរាប់កសាង ឬ ពង្រឹងអំណាច បក្ស។ ដូច្នេះ ចំពោះពួកកុម្មុយនិស្ត គោលដៅរបស់សង្គ្រាម វាគ្មានទីបញ្ចប់ទេ ព្រោះ អំណាចត្រូវការរក្សាវាគ្រប់ពេលវេលា។ ដូច្នេះ នៅពេលគ្មានសង្គ្រាម បក្សកុម្មុយនិស្ត កាន់អំណាច តែងតែមានអារម្មណ៏ នៃប្រទូសភាព ជានិច្ចដើម្បី បង្ហាញ នូវ ការផ្តុយគ្នាខ្លាំងបំផុត ឬ ជា

រូបភាព នៃគំនិតដាច់ខាត របស់ខ្លួន ចំពោះ គូប្រយុទ្ធ សិប្បនិម្មិត ដែលខ្លួនឯង ជាអ្នកបង្កើតឡើង ហើយ ជារឿយៗ គឺ ទុកប្រជាពលរដ្ឋ ជាសត្រូវនឹងបក្សខ្លួនតែម្តង។

សង្គ្រាម ដែលពួកយួនកុម្មុយនិស្ត បង្កើតឡើងនៅស្រុកខ្មែរចាប់ពីឆ្នាំ ១៩៧០ រហូតដល់ឆ្នាំ ១៩៩១ ប្រឆាំងនឹងប្រជាជាតិខ្មែរ មានធាតុបីយ៉ាង: ជាសង្គ្រាមឈ្លានពាន ជាសង្គ្រាមតម្រង់នឹងកាន់កាប់ស្រុកខ្មែរ និង ជាសង្គ្រាមនៃកុម្មុយនិស្តនិយម។ នៅពេលសង្គ្រាមម្តង ពួកយួនកុម្មុយនិស្ត មានលទ្ធភាព អាចបំបែកប្រជាជាតិខ្មែរបានជានិច្ច នាំអោយខ្មែរ បាត់កម្លាំងតស៊ូរួម ទោះបីខ្មែរជាទូទៅ ធ្លាប់ស្គាល់ និង មានការពិសោធ លើល្បិចបំបែកបំបាក់ខ្មែរ របស់យួនយ៉ាងណាក៏ដោយ។ ដូច្នោះទេឬ ជាចំណុចខ្សោយខ្មែរ ដែលយួនគេរកឃើញ ? យួន អាចប្តូររូបភាពសង្គ្រាមតស៊ូខ្មែរ នៅសម័យសាធារណរដ្ឋខ្មែរ ឲទៅជាសង្គ្រាមស៊ីវិល រវៀងខ្មែរនឹងខ្មែរ ព្រោះយួន ល្បួងសម្តេចសីហនុ យកមកប្រើសំរាប់ ការពារប្រយោជន៍យួន និង បញ្ជោតពួកខ្មែរក្រហម ឲជួយខ្លួន ក្នុងនាម សាមគ្គីភាពកុម្មុយនិស្ត វាយចក្រពត្រអាមេរិកាំង។ នៅសម័យខ្មែរ

ក្រហម យួនបង្កើតប្រទូសភាព ព្រំដែន ដើម្បីទាញពួកខ្មែរក្រហម ឲប្រព្រឹត្តកំហុស ជាយុទ្ធសាស្ត្រ និង ការទូត ដែលគេអាចយកជាលេស សំរាប់វាយ យកស្រុកខ្មែរ នៅឆ្នាំ ១៩៧៩ បានយ៉ាងងាយស្រួលបំផុត។ នៅសម័យ យួនកាន់កាប់ស្រុកខ្មែរ គេឆ្លៀតទាញយកប្រយោជន៏ គ្រប់បែបយ៉ាងពីខ្មែរ ព្រោះប្រជាពលរដ្ឋខ្មែរ ត្រូវការរស់រស់ថិញ្ចឹមក្រពះ បន្ទាប់ពីរួចចេញពីរបបជនឃាត។ ជាថ្មីម្ដងទៀតនៅក្នុងការរៀបចំកិច្ចព្រមព្រៀងសន្តិភាព យួន អាចប្ដូររូបភាពសង្គ្រាមឈ្លានពាន របស់ខ្លួន ឲទៅជាសង្គ្រាម រវាងភាគីប្រដាប់អាវុធខ្មែរ ដោយយកសម្ដេច សីហនុ ជាអ្នកសំដែងតួជាអ្នកផ្សះផ្សាជាតិខ្មែរ តែតាមពិត ជាការបោកប្រាស ដើម្បីទាក់ព្រះអង្គ ឲមកបំរើប្រយោជន៏តែប៉ុណ្ណោះ។ សព្វថ្ងៃ យួន គេប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីធ្វើឲស្រុកខ្មែរ លែងមានលក្ខណ: ជាប្រជាជាតិ។ ពលរដ្ឋខ្មែរសព្វថ្ងៃ រស់ជា ជាតិពិន្ទុមួយ នៅក្នុងទឹកដី ដែលមានយួនជាម្ចាស់ដាច់ថ្លៃ។ តើមិនមែនជាការចាប់ផ្ដើម នៃចុងបញ្ចប់នៃប្រជាជាតិខ្មែរ ? ចម្លើយគឺនៅលើ ប្រជាពលរដ្ឋខ្មែរខ្លួនឯង។ បើជនខ្មែរទាំងឡាយ អង្គុយរង់ចាំ ចម្លើយបរទេស

ដូចយ៉ាង សហរដ្ឋអាមេរិក និង សហភាពអឺរ៉ុប គឺចុងបញ្ចប់ វាច្បាស់នឹងមកដល់ជាពុំខាន ព្រោះ ស្រុកខ្មែរកំពុងដើរ យ៉ាងប្រញាប់បំផុតទៅរកវា ដ្បិតសង្គមខ្មែរសព្វថ្ងៃលែងមាន ប្រជាកម្លាំងខ្មែរ សំរាប់ការពារប្រជាជាតិខ្លួន។ បនភ្នំពេញក្តី គណបក្សប្រឆាំងក្តី វាគ្រាន់តែជាឧបករណ៏នៃនយោបាយម៉ឺនឆ្នាំ របស់យួនតែប៉ុណ្ណោះ។ ការព្យាយាមរបស់យួន វាកំពុងផ្តល់ នូវសុផាតផលដល់គេ។ រិត្ថារកថា (ពាក្យពិស្តា) ថា បើវាមានការយឺនយូរ វាប្រសើរជាងមិនធ្វើ (il vaut mieux tard que jamais) តើវាជាពាក្យសំរាប់ចង្អុលផ្លូវ សំរាប់ប្រជាពលរដ្ឋខ្មែរ ដែរឬទេ ?



នៅភូមិ FERE-EN-TARDENOIS នៅស្រុកបារាំង ថ្ងៃ២ ធ្នូ ១៩៨៧ នៅពេលជំនួប រវាង សម្តេច សីហនុ និង ហ៊ុន សែន

## ឧបសម្ព័ន្ធ

សហរដ្ឋអាមេរិក ធ្លាប់មានជ័យជំនះ នៅក្នុងសង្គ្រាមនៅប្រទេសកូរ៉េ គឺថា អាចរុញច្រាន កងទ័ពកូរ៉េខាងជើង វាយលុកចូលមកក្នុងទឹកដីកូរ៉េខាងត្បូង តែនៅពេលនោះដែរក៏គេអាចចាត់ទុកចិនប្រជាមានិត ជាអ្នកមានជ័យជំនះដែរ ព្រោះ អន្តរាគមន៍ផ្ទាល់ នៃកងទ័ពចិននៅកូរ៉េខាងជើង អាចខាឃាំងកងទ័ពអាមេរិកាំង មិនឲបន្តសង្គ្រាមរហូតកាន់កាប់កូរ៉េខាងជើងតែម្តង ព្រោះកងទ័ពអាមេរិកាំង អាចមានលទ្ធភាពនឹងអាច វាយយកកូរ៉េខាងជើងតែម្តង បើនៅពេលនោះ មានការអនុញ្ញាតពីលោកប្រធានាធិបតីអាមេរិកាំង។ ដូច្នោះ ជ័យជំនះអាមេរិកាំងទុកជាជ័យជំនះយោធា រីឯជ័យជំនះចិន អាចចាត់ទុកជាជ័យជំនះនយោបាយ។ តែនៅក្នុងករណីណាក៏ដោយ ជ័យជំនះទាំងពីរនេះ គឺត្រួតត្រាដោយនយោបាយ ព្រោះ នៅទីបញ្ចប់ មានការចរចា សំរាប់ស្វែងរកសន្តិភាពសម្របសម្រួល រវាង ចិន និង អាមេរិកាំង ហើយនិង រវាង កូរ៉េខាងជើង និង កូរ៉េខាងត្បូង ដើម្បីបញ្ចប់សង្គ្រាមតាមសន្តិវិធី។ ជាការពិត សង្គ្រាមនៅយៀកណាម សហរដ្ឋអាមេ

រិក រើសយក យុទ្ធសាស្ត្រ និង ការទូត ប្រហាក់ប្រហែលនឹង សង្គ្រាមនៅកូរ៉េ គឺក្នុងនយោបាយ ទប់ទល់ ការរីកសាយលទ្ធិកុម្មុយនិស្ត នៅដំបន់អាស៊ីទាំងមូល ដោយប្រើកម្លាំងយោធាច្រើនសម្បើម វាយតបកម្លាំងយៀកកុងនៅយៀកណាមខាងត្បូង និង ទម្លាក់គ្រាប់បែក នៅយៀកណាមខាងជើង ដែលជា អ្នកផ្តល់ជំនួយធនធានមនុស្ស ដល់ពួកយៀកកុង ដើម្បីបង្ខំយួនកុម្មុយនិស្ត និង សម្ពន្ធមិត្តជាពិសេសចិនប្រជាមានិត អោយចរចា បញ្ឈប់សង្គ្រាមតាមសន្តិវិធី។ បរាជ័យ នៃយួនកុម្មុយនិស្ត នៅឆ្នាំ ១៩៦៨ ក្នុង ការវាយប្រហារយោធា ដ៏ធំមួយនៅយៀកណាមខាងត្បូង[40] ក្នុងគោលដៅ ឲប្រជាជនយួនខាងត្បូង ងើបឡើង

[40] នៅថ្ងៃទី៣០ មករា ឆ្នាំ ១៩៦៨ មួយថ្ងៃមុនបុណ្យព្រះខែ (Têt) កងទ័ពយួនកុម្មុយនិស្ត ចំនួន ៨ ម៉ឺននាក់ បើកការវាយប្រហារ ទៅលើទីក្រុងប្រមាណជាង១០០។ ការវាយលុកនេះ ធ្វើអោយមានការភ្ញាក់ដោយមិនដឹងខ្លួន នៃកងទ័ពអាមេរិកាំង និង យួនខាងត្បូងពិត តែ កងទ័ពទាំងពីរវាយទប់យ៉ាងស្វិតស្វាញបាន នាំអោយកងទ័ពយួនកុម្មុយនិស្ត ទទួល នូវការខូចខាត និង បាត់បង់ជីវិតច្រើនក្រៃលែង។ ម្យ៉ាងមួយទៀត ការនឹកស្មានថានឹងមានការបះបោរជាទូទៅ នៃប្រជាជន ក៏គ្មានមានកើតឡើងនោះដែរ។ យុទ្ធសាស្ត្រវាយប្រហារ សំរាប់ ជ័យជំនះរហ័ស នេះ គឺលោក Le Duan

បះបោរជាទូទៅ ប្រឆាំងនឹងរដ្ឋាភិបាល ដើម្បីរំលំ របបសាធារណរដ្ឋ យៀកណាមខាងត្បូង បង្ខំចិត្ត ពួកកុម្មុយនិស្តយួន អោយប្តូរយុទ្ធសាស្ត្រ ពីការវាយប្រហារតាមផ្លូវយោធា យកឈ្នះឆាប់រហ័ស មករក ការយកឈ្នះតាមដំណាក់ការ គឺ ប្រើកម្លាំងយោធាផង និង ការចរចាផង ដើម្បីធ្វើយ៉ាងណា អោយអាមេរិកាំង ដកកងទ័ពចេញពីយៀកណាមខាងត្បូងសិន បន្ទាប់មក ទើបវាយកងទ័ពយួនខាងត្បូងយកឈ្នះតែម្តង។ ដូច្នោះ កិច្ចព្រមព្រៀងសន្តិភាព ដែលពួកយួនកុម្មុយនិស្ត សុខចិត្ត ចុះហត្ថលេខាជាមួយ សហរដ្ឋអាមេរិក នៅថ្ងៃទី ២៧ មករា ឆ្នាំ ១៩៧៣ នៅទីក្រុងប៉ារីស គឺប្រព្រឹត្តឡើងនៅក្នុងគោលគំនិតនោះឯង។ សួរថា តើ អាមេរិកាំង ចាញ់បោកយួន ? ចម្លើយ គឺ អាមេរិកាំង មិនចាញ់បោកយួនកុម្មុយនិស្តនោះទេ តែ

---

ជាអ្នកផ្តើមគំនិត ដែលនាំអោយគាត់ទទួល នូវការរិះគន់យ៉ាងខ្លាំង។ តែបន្ទាប់ពីការវាយប្រហារនោះមក មតិ នៃប្រជាពលរដ្ឋអាមេរិកាំង ប្រឆាំងនឹង សង្គ្រាមនៅយៀកណាម ក៏កាន់តែមានចំនួនកើនច្រើនឡើងដែរ។ បញ្ហាការជាន់ខ្ពស់ នៃកងទ័ព ក៏ទទួល នូវការរិះគន់ខ្លាំង ពីសំណាក់សាធារណៈជន។

គោលចំណង់អាមេរិកាំង គឺបោះបង់ចោល ឥណ្ឌូចិន តែម្ដង មិនមែនគ្រាន់តែបោះបង់ របបសេរី នៅ ស្រុក យួន ខ្មែរ និង លាវ ប៉ុណ្ណោះទេ គឺ បោះបង់ ប្រជាជន ភាគច្រើន នៃប្រទេសទាំងបី ដែលមាន ជំនឿដោយគ្មានមន្ទិល លើ កម្លាំងអាមេរិកាំង ថានឹងអាចទប់ទល់ កម្លាំងកុម្មុយនិស្តបាន ដើម្បី សេរីភាព និង លទ្ធិប្រជាធិបតេយ្យ។ សភាអាមេរិកាំង បោះបង់ប្រជាពលរដ្ឋឥណ្ឌូចិន លើវេទី នៃសេចក្ដីសុខអាមេរិកាំង (tranquillité américaine) គឺការដោះដូរជាមួយយួនកុម្មុយនិស្ត នៃអ្នកទោសយោធាអាមេរិកាំង ដែល ជាប់ឃុំឃាំង នៅក្នុងជំរុំគុក របស់ពួកកុម្មុយនិស្ត។ នៅស្រុកខ្មែរ ចាប់ពីថ្ងៃទី១៥ សីហា ឆ្នាំ ១៩៧៣ សភាអាមេរិកាំង ហាមដាច់ខាត មិនអោយកងទ័ពអាកាសអាមេរិកាំង មានសកម្មភាពនៅស្រុកខ្មែរ មិនថែមតែប៉ុណ្ណោះ សភាអាមេរិកាំង ប្រកាសកាត់ជំនួយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដល់ សាធារណរដ្ឋខ្មែរ និង សាធារណរដ្ឋវៀតណាមខាងត្បូង ថែមទៀត។ ចាប់ពីឆ្នាំ ១៩៧៣មក ទឹកដីឥណ្ឌូចិន បានក្លាយជាវាលប្រមាញ់ នៃបក្សកុម្មុយនិស្តយួនតាមសេរី៕